ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# នីតិវិធីសង្ខេបៈ
# រដ្ឋប្បវេណី និង ព្រហ្មទណ្ឌ

## (សម្រាប់អនុវត្តនៅតាមសាលាជម្រះក្ដីនានា)

សរសេរឡើងដោយៈ លោក **ជួន សុរាសី**
ចៅក្រម សាលាដំបូងរាជធានីភ្នំពេញ
សាស្ត្រាចារ្យ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
និង សាកលវិទ្យាល័យមេគង្គកម្ពុជា

(រក្សាសិទ្ធិគ្រប់បែបយ៉ាង)
បោះពុម្ពលើកទី២
ខែកញ្ញា ឆ្នាំ២០១១

7.10.2011 សិស្សឆ្នាំទី4.

# មាតិកា

## ជំពូក១: នីតិវិធីរដ្ឋប្បវេណីសង្ខេប សម្រាប់អនុវត្តក្នុងរឿងក្តីរដ្ឋប្បវេណី:  ទំព័រ


ផ្នែកទី១: នីតិវិធីនៃការដាក់ពាក្យបណ្តឹង............ ១

ផ្នែកទី២: នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល............ ៥

ផ្នែកទី៣: ការទាញហេតុផលផ្ទាល់មាត់............ ៨

ផ្នែកទី៤: នីតិវិធីបញ្ចប់ការដោះស្រាយបណ្តឹង............ ១១

ផ្នែកទី៥: ការចាត់ចែងរក្សាការពារ............ ១៥

ផ្នែកទី ៦: នីតិវិធីអនុវត្តដោយបង្ខំ............ ២៤


## ជំពូក២: នីតិវិធីព្រហ្មទណ្ឌសង្ខេប សម្រាប់អនុវត្តក្នុងរឿងក្តីព្រហ្មទណ្ឌ:


ផ្នែកទី១: នគរបាលយុត្តិធម៌............ ៣៦

ផ្នែកទី២: អយ្យការ............ ៤៣

ផ្នែកទី៣: ចៅក្រមស៊ើបសួរ............ ៤៥

ផ្នែកទី៤: ចៅក្រមជំនុំជម្រះ............ ៥១

ផ្នែកទី៥: នីតិវិធីសម្រាប់បណ្តឹងឧបាស្រ័យ............ ៥៣

# ជំពូក ១

# និតិវិធីរដ្ឋប្បវេណីសង្ខេប

## សម្រាប់អនុវត្តក្នុងរឿងក្ដីរដ្ឋប្បវេណី
## តាមសាលាជម្រះក្ដីនានា

# ផ្នែកទី១: នីតិវិធីនៃការដាក់ពាក្យបណ្តឹង

## ១. ការដាក់ពាក្យបណ្តឹង

- នីតិវិធីរដ្ឋប្បវេណីទៅតុលាការ ត្រូវចាប់ផ្តើមពេលដាក់ពាក្យបណ្តឹង
- ពាក្យបណ្តឹងដាក់ជាលាយលក្ខណ៍អក្សរទៅតុលាការ ម.៧៥/១ លើកលែងរឿងក្តីមានចំនួនទឹកប្រាក់តិច ម.២២៥/១
- ពាក្យបណ្តឹងចាត់ទុកថាបានដាក់ នៅពេលក្រឡាបញ្ជីបោះត្រាចូលថាបានទទួល។

## ២. ពាក្យបណ្តឹង

### ២.១ ចំនុចត្រូវសរសេរក្នុងពាក្យបណ្តឹង ម.៧៥/២

ក. ភាគី អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងនៃនីតិបុគ្គល

- សរសេរឈ្មោះ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ឬ អ្នកតំណាងច្បាប់បានកំណត់ ម.៧៥/២.ក
- ករណីភាគីជានីតិបុគ្គល ត្រូវសរសេរពីអ្នកតំណាងនីតិបុគ្គលនោះ ម.៣៨ និង ៧៥/២.ក

ខ. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ និងអង្គហេតុចំបាច់ដើម្បីបញ្ជាក់ការទាមទារ

ម.៧៥/២.ខ: គឺជាអត្ថន័យនៃសាលក្រម ដែលដើមចោទទាមទារឲ្យតុលាការសម្រេចសេចក្តី ដូចក្នុងពាក្យបណ្តឹងខ្លួន។ ឧទាហរណ៍:

- បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក
- បណ្តឹងទាមទារឲ្យបញ្ជាក់ពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនិងទំនាក់ទំនងគតិយុត្ត
- បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត។

ម.៧៥/២.ខ: អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ គឺជាអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារតាមផ្លូវបណ្តឹង ហើយក៏កុំឲ្យមានការភាន់ច្រឡំ ឬ មានការបែងចែកមិនច្បាស់លាស់នូវការទាមទារ ដែលជាកម្មវត្ថុនៃការជំនុំជម្រះ និងសម្រេចសេចក្តីទៅនឹងការទាមទារផ្សេងទៀត និងកុំឲ្យមានការភាន់ច្រឡំរវាងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលអះអាងដោយដើមចោទ និងសិទ្ធិទំនាក់ទំនងគតិយុត្តដទៃទៀត។

ឧទាហរណ៍: *ការអះអាងសិទ្ធិលើបំណុលផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ។*

២.២ ចំណុចគប្បីសរសេរក្នុងពាក្យបណ្ដឹង ម.៧៥/៣

- អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុបង្កើតនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាសិទ្ធិទាមទារតាមផ្លូវបណ្ដឹង។

- អង្គហេតុបង្កើតសិទ្ធិ: កិច្ចសន្យាខ្ចីប្រាក់ ៥,០០០ ដុល្លារ
- អង្គហេតុបង្កើតឧបសគ្គនៃការកកើតសិទ្ធិ: កិច្ចសន្យាមានវិការៈ
- អង្គហេតុរំលត់សិទ្ធិ : ចុងចម្លើយបានសងប្រាក់ ៥,០០០ ដុល្លា រួចហើយ
- អង្គហេតុបង្កើតការរារាំងការអនុវត្តសិទ្ធិ : កាលកំណត់សងមិនទាន់មកដល់

} អង្គហេតុតវ៉ារបស់ចុងចម្លើយ

- អង្គហេតុសំខាន់ៗក្នុងចំនោមអង្គហេតុទាំងមូល ដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង ម.៧៥/៣: អង្គហេតុប្រយោល ដែលអាចធ្វើឲ្យគេសន្និដ្ឋានពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុចម្បង (អង្គហេតុផ្ទាល់) ។ អង្គហេតុប្រយោល ជាច្រើនអាចបង្កើតជាអង្គហេតុផ្ទាល់តាមភស្តុតាង។

៣. ការទទួលពាក្យបណ្ដឹង

៣.១. នីតិវិធីនៃការទទួលពាក្យបណ្ដឹង: ក្រឡាបញ្ជីត្រូវ:

- វាយត្រាលើពាក្យបណ្ដឹង និងចុះកាលបរិច្ឆេទនៃការទទួល
- ចុះលេខរៀងនៅក្នុងសៀវភៅពាក្យបណ្ដឹង
- យកពាក្យបណ្ដឹង និងឯកសារពាក់ព័ន្ធមកដាក់បញ្ចូលក្នុងក្របសំណុំរឿង
- បញ្ជូនសំណុំរឿងក្ដីនោះទៅចៅក្រមទទួលបន្ទុក ទៅតាមដីកាសម្រេចប្រចាំឆ្នាំ
- មុនពេលបញ្ជូន ក្រឡាបញ្ជី គួរពិនិត្យមើលពាក្យបណ្ដឹងមួយត្រួសសិន ទាក់ទងនឹងការសរសេរពាក្យបណ្ដឹងតាម ម.៧៥/២ និងអំពីសមត្ថកិច្ចជម្រះក្ដី ម.៨, ម.៩ ឬអត់ និងលិខិតបញ្ជាក់សិទ្ធិតំណាងជាដើម។ ក្នុងករណីបើមានចំនុចខ្វះខាត ក្រឡាបញ្ជីគួរ (មិនមែនជាកាតព្វកិច្ចទេ) ប្រាប់ដើមចោទឲ្យកែតម្រូវ តែពុំមានសិទ្ធិមិនទទួលពាក្យបណ្ដឹង ឬ លើកចោលពាក្យបណ្ដឹងទេ មានតែចៅក្រមទេដែលមានសិទ្ធិសម្រេច។

៣.២. ឯកសារភ្ជាប់ជាមួយពាក្យបណ្ដឹង:

- លិខិតចម្លងនៃពាក្យបណ្ដឹង

- លិខិតចម្លងនៃឯកសារភស្តុតាង

- ឯកសារបញ្ជាក់សិទ្ធិតំណាង

៣.៣ ពន្ធដាក់ពាក្យសុំ និងប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ:

- ពន្ធដាក់ពាក្យសុំកំណត់ទៅតាមទំហំកម្មវត្ថុនៃពាក្យបណ្តឹង ម.៦១ (មានសៀវភៅកំណត់ពន្ធរបស់ក្រសួងយុត្តិធម៌)
- ការជួយសង្គ្រោះពន្ធលើពាក្យបណ្តឹង ម.៦៩
- ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ: ម.៦២ សម្រាប់ពិនិត្យភស្តុតាង បញ្ជូនឯកសារ និងសោហ៊ុយធ្វើដំណើរ។

## ៤. ការបែងចែករឿងក្តី ម.២៦

- បែងចែករឿងក្តីតាមលំដាប់កំណត់ជាមុនតាមដីកាសម្រេចរបស់ប្រធានតុលាការជារៀងរាល់ឆ្នាំ។
- បែងចែកឲ្យចៅក្រម ១នាក់ ឬ ក្រុមប្រឹក្សាជំនុំជម្រះ ម.២៣ ក្នុងករណីរឿងនោះមានភាពស្មុគស្មាញ ដែលនឹងត្រូវឲ្យសម្រេចដោយចៅក្រម៣នាក់ដូចជា: បណ្តឹងផិតចិត្ត ឬ ពាក្យសុំដកហូតចៅក្រម ជាដើម ម.៣០ ។ ៥៤៧

## ៥. ការពិនិត្យពាក្យបណ្តឹង

៥.១ វិធីពិនិត្យ: ម.៧៨

ជាការពិនិត្យលើចំនុចដែលត្រូវសរសេរតាម ម.៧៥/២ (ក & ខ) និងពន្ធដាក់ពាក្យសុំ ម.៦១ បង់ហើយឬនៅ។ ការពិនិត្យនេះ គឺដើម្បីចេញដីកាបង្គាប់ឲ្យកែតម្រូវ និងដីកាសម្រេចលើកពាក្យបណ្តឹងចោល ម.៧៨/១ និង២។ ការពិនិត្យពាក្យបណ្តឹងដើម្បីដឹកនាំរឿងក្តីឲ្យបានឆាប់រហ័ស។

៥.២ ដីកាបង្គាប់ឲ្យកែតម្រូវ និង ដីកាសម្រេចលើកពាក្យបណ្តឹងចោល:

- ដីកាបង្គាប់ឲ្យកែតម្រូវ ម.៧៨/១: ពាក្យបណ្តឹងផ្ទុយនឹង ម.៧៥/២ តុលាការកំណត់រយៈពេលសមរម្យ និងបង្គាប់ឲ្យកែតម្រូវចំនុចខ្វះខាត និងការអនុវត្តចំពោះពន្ធដាក់ពាក្យសុំផងដែរ ម.៦១។

- ដីកាសម្រេចលើកពាក្យបណ្តឹងចោល ម.៧៨/២: បើដើមចោទមិនកែតម្រូវនឹងដីកាបង្គាប់ខាងលើ ចៅក្រមអាចចេញដីកាសម្រេចលើកពាក្យបណ្តឹងចោល តែអាចប្តឹងទាស់បាន ម.៧៨/៣។

## ៦. ការពិនិត្យលក្ខខណ្ឌបណ្ដឹង

៦.១ **អត្ថន័យ** គឺជាលក្ខខណ្ឌដើម្បីចេញសាលក្រម ដែលសម្រេចអំពីអង្គសេចក្ដី

- តុលាការព្រះរាជាណាចក្រកម្ពុជា ជាតុលាការមានសមត្ថកិច្ចជំនុំជម្រះ (ចាប់ពី ម.៧ ទៅ)
- តុលាការដែលចាត់ការត្រូវមានសមត្ថកិច្ចលើរឿងក្ដីនោះ (ចាប់ពី ម.៧ ទៅ)
- មានភាគីពិតប្រាកដ ហើយមានសមត្ថភាព ម.៣២
- មានផលប្រយោជន៍នៃបណ្ដឹង ម.៧៤
- បណ្ដឹងដែលច្បាប់មិនហាមឃាត់ ម.៨៣
- ពុំមានការហាមឃាត់នូវការធ្វើបណ្ដឹងនោះតាមរយៈកិច្ចសន្យារវាងភាគី ម.៣៨៥/២ ក្រមរដ្ឋ.ណី

៦.២ **ការពិនិត្យលក្ខខណ្ឌបណ្ដឹង**

- កង្វះលក្ខខណ្ឌបណ្ដឹង ហើយមិនអាចកែតម្រូវបាន លើកបណ្ដឹងចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន ម.៨១។ ករណីពាក្យបណ្ដឹងបញ្ជូនទៅចុងចម្លើយហើយ ទោះបីពាក្យបណ្ដឹងមានចំនុចខ្វះខាតតាម ម.៧៥/២ ក៏ដោយ ក៏តុលាការចេញសាលក្រមលើកបណ្ដឹងចោល។

## ៧. ការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល: ម.៨០

ក្រោយពីពិនិត្យពាក្យបណ្ដឹង បើយល់ឃើញថាពាក្យបណ្ដឹងស្របច្បាប់ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀម និងចេញដីកាកោះហៅភាគីទាំងសងខាងឲ្យបង្ហាញខ្លួននៅតុលាការ តាមកាលបរិច្ឆេទដែលបានកំណត់។ ការកំណត់កាលបរិច្ឆេទនេះ ត្រូវធ្វើក្នុងអំឡុងពេល ៣០ថ្ងៃ គិតពីថ្ងៃដាក់ពាក្យបណ្ដឹង លើកលែងតែករណីមានមូលហេតុពិសេស ទើបកំណត់អំឡុងពេលលើសពី៣០ ថ្ងៃបាន។

## ៨. ការបញ្ជូនពាក្យបណ្ដឹង

- ម.៧៨/១ ត្រូវបញ្ជូនពាក្យបណ្ដឹងទៅចុងចម្លើយជាការចាំបាច់ ព្រោះវាផ្ដល់ឱកាសឲ្យភាគីម្ខាងទៀត ឆ្លើយដោះសារ និងរៀបចំមធ្យោបាយសម្រាប់ការពារខ្លួន។

- ករណីពាក្យបណ្ដឹងមិនអាចបញ្ជូនបាន ដោយសារអាសយដ្ឋានចុងចម្លើយ ដែលដើមចោទផ្ដល់មកមិនច្បាស់លាស់ជាដើម តុលាការអាចបង្គាប់ឲ្យដើមចោទកែតម្រូវអាសយដ្ឋាន ហើយបើមិនកែតម្រូវចេញ ចៅក្រមអាចចេញដីកាសម្រេចលើកពាក្យបណ្ដឹងចោល ម.៧៨/២។

# ផ្នែកទី២: នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

## ១. គោលបំណង

ជានីតិវិធី ដើម្បីរៀបចំនូវការអះអាងរបស់ភាគី និងរៀបចំនូវចំនុចវិវាទនៃរឿងក្តី ព្រមទាំងរៀបចំនូវភស្តុតាងដែលពាក់ព័ន្ធនឹងចំនុចវិវាទ ដើម្បីឱ្យតុលាការធ្វើការពិនិត្យភស្តុតាងជាសមូហវិធី នៅក្នុងនីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ម.១០៣ ។

## ២. គោលការណ៍ចំពោះមុខ និងគោលការណ៍បើកជាសាធារណៈ:

- គោលការណ៍ចំពោះមុខ :

ម.១០៥: នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ធ្វើឡើងនៅកាលបរិច្ឆេទ ដែលភាគីសងខាងអាចចូលរួមបាន។

ម.១០៣: ក្នុងករណីណាក៏ដោយតុលាការត្រូវគោរពគោលការណ៍ចំពោះមុខ ម.៣។

- គោលការណ៍បើកជាសាធារណៈ: នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់ធ្វើជាសាធារណៈទេ ម.១០៥/២។

## ៣. កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល:

### ៣.១ ការសាកល្បងផ្សះផ្សា (រួមទាំងវិធីសាស្ត្រនៃការផ្សះផ្សា)

- ម.១០៤: នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាមុនសិនតាមឆន្ទៈភាគី ឬ តុលាការ (តុលាការគប្បីជ្រើសរើសនូវវិធីសាស្ត្រដ៏ល្អមួយ)
- ម.៩៧ : តុលាការធ្វើការផ្សះផ្សាទោះបីជាបណ្តឹងស្ថិតក្នុងដំណាក់កាលណាក៏ដោយ
- ប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ០៤/៨៤ និងមាត្រា ៤៥ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ១៩៨៩។

### ៣.២ សេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹង

- ដើមចោទធ្វើសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹង:
  - ខ្លឹមសារនៃសាលក្រមដែលទាមទារឱ្យតុលាការចេញ
  - អង្គហេតុចាំបាច់សម្រាប់ការទាមទារ
  - អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗ និងភស្តុតាង

### ៣.៣ សេចក្តីថ្លែងការណ៍អំពីឯកសារចម្លើយ

- ចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍អំពី ឯកសារចម្លើយដើម្បីឆ្លើយតប និងការទាមទាររបស់ដើមចោទ

- ឯកសារចម្លើយជាឯកសារត្រៀមដែលចុងចម្លើយដាក់លើកដំបូង ម.១០១/៣

- ឯកសារត្រៀម: ជាឯកសារដែលសរសេរអំពីខ្លឹមសារ ដែលភាគីនឹងថ្លែងការណ៍នៅកាលបរិច្ឆេទបន្ទាប់ ដើម្បីជូនដំណឹងទៅភាគីម្ខាងទៀត និងទៅតុលាការផងដែរ។

- ក្នុងឯកសារត្រៀម ត្រូវសរសេរពីមធ្យោបាយតទល់ ឬ ការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត ម.១០១/២។

- មធ្យោបាយតទល់: ជាឯកសារទាំងឡាយដែលដើមចោទបានដាក់ជូនទៅតុលាការ ដើម្បីបញ្ជាក់ពីមូលហេតុនៃការទាមទាររបស់ខ្លួន។

- មធ្យោបាយការពារខ្លួន : ជាឯកសារទាំងឡាយដែលចុងចម្លើយបានដាក់ជូនតុលាការ ដើម្បីបញ្ជាក់ថាការទាមទាររបស់ដើមចោទ ពុំមានមូលហេតុត្រឹមត្រូវ។ គួរកត់សំគាល់ផងដែលថា ទាំងមធ្យោបាយតទល់ និងការពារខ្លួន ទាំងដើមចោទ និងចុងចម្លើយ អាចដាក់ទៅវិញទៅមកបាន។

- ចុងចម្លើយតប (ឯកសារចម្លើយ) នឹងការទាមទាររបស់ដើមចោទមាន ៣ចំនុច :
  - ទទួលស្គាល់នូវការទាមទារ ម.២២១ កំណត់ហេតុ ដូចសាលក្រមស្ថាពរ ម.២២២
  - ឲ្យច្រានចោលនូវការទាមទារ ដោយគ្មានមូលហេតុនៃការទាមទារ
  - លើកបណ្តឹងចោល ដោយសារពុំមានមូលហេតុនៃបណ្តឹង

- របៀបនៃការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ចុងចម្លើយ
  - ការសារភាព ម.១២៣/២ មិនចាំបាច់បញ្ជាក់ដោយភស្តុតាង
  - *ការបដិសេធ ម.១២៣/១ (តវ៉ា : ត្រូវបញ្ជាក់ដោយភស្តុតាង)*
  - *មិនដឹង* ម.៨៦/២ *(តវ៉ា : ត្រូវបញ្ជាក់ដោយភស្តុតាង)*
  - នៅស្ងៀមមិនបង្ហាញឆន្ទៈ ម.៨៦/១ (ចាត់ទុកថាសារភាព មិនបញ្ជាក់ដោយភស្តុតាងទេ)

### ៣.៤ ភស្តុតាង

មេរៀន ១២.

- ភស្តុតាងមាន ៥ប្រភេទ : ការសួរសាក្សី ម.១៣២, សាមីភាគី ម.១៤០, កោសលវិច័យ ម.១៤៣, ឯកសារ ម.១៤៨ និងការត្រួតពិនិត្យ (វត្ថុ) ម.១៦១។
- នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការពុំអាចពិនិត្យភស្តុតាងបានទេ លើកលែងតែភស្តុតាងជាឯកសារដែលការពិនិត្យមានកំរិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទ ម.១០៦។
- ភាគីត្រូវស្នើសុំពិនិត្យភស្តុតាង បើភស្តុតាងជាសាក្សី ឬ សាមីភាគីត្រូវរៀបចំនូវកម្រងសំនួរ។
- ចៅក្រមត្រូវសម្រេចទទួលយក ឬ មិនទទួលយកការស្នើសុំដោយផ្ទាល់មាត់ ឬ ដីកាសម្រេច បើផ្ទាល់មាត់ត្រូវសរសេរក្នុងកំណត់ហេតុ ម.១០៦ និង ១២៦។

៣.៥ <u>ការកំណត់កាលបរិច្ឆេទបន្ទាប់ និងចំនុចដែលឲ្យភាគីត្រៀម</u>

- ករណីតុលាការពុំទាន់អាចកំណត់ចំនុចវិវាទបាន គឺឲ្យភាគីដាក់ឯកសារត្រៀម សម្រាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២
- នៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២: ដើមចោទធ្វើសេចក្តីថ្លែងការណ៍អំពីឯកសារត្រៀមទី១ (ចុងចម្លើយដូចគ្នា)
- ការស្នើសុំពិនិត្យភស្តុតាងបន្ថែមទៀតបើមាន ចៅក្រមសម្រេច (តុលាការដឹកនាំ និងសិទ្ធិបំភ្លឺ ម.៨៩)។

៣.៦ <u>ការបញ្ជាក់ពីអង្គហេតុត្រូវបំភ្លឺ (បញ្ជាក់ដោយភស្តុតាង)</u>

ពេលរៀបចំចំណុចវិវាទបានរួចហើយ មុននឹងបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវបញ្ជាក់ជាមួយភាគីអំពីអង្គហេតុដែលត្រូវបំភ្លឺ ម.១០៧ ដើម្បីយកទៅពិនិត្យភស្តុតាងជាសមូហវិធីក្នុងនីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ម.១០៣ និង ១២៧។

៣.៧ <u>អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល:</u>

ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន សារជាថ្មីបានទេលើកលែង ៖

- ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់តុលាការ ម.១៦, ម.១៧ (រឿងសមត្ថកិច្ច, ការដកហូតចៅក្រម)
- ពុំធ្វើឲ្យមានការយឺតយ៉ាវដល់នីតិវិធីបណ្តឹង (សាក្សីទើបរកឃើញ, ឯកសារទើបចាក់សោរបាន)
- ភាគីគ្មានកំហុសធ្ងន់ធ្ងរ

៣.៨ កំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការកំណត់កាលបរិច្ឆេទ នីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ទី១:

នៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនីមួយៗ តុលាការត្រូវឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុ ព្រោះថាមានសកម្មភាពជាច្រើនរបស់ភាគី និងតុលាការដូចជា៖ ការអះអាង, ការទទួលស្គាល់, ការលះបង់នូវការទាមទារ, ការរៀបចំចំណុចវិវាទជាដើម ព្រោះថាកំណត់ហេតុនឹងក្លាយជាលទ្ធផល ដែលភាគីនឹងត្រូវធ្វើសេចក្តីថ្លែងការណ៍នៅកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ទី១ ម.១១៦/១។ កំណត់ហេតុ មានចំណុចជារូបមន្ត និងចំនុចជាសារធាតុ ហើយចុះហត្ថលេខាដោយក្រឡាបញ្ជី និងចៅក្រម ម.១១០ និង ម.១១១។ នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានបញ្ចប់សព្វគ្រប់ហើយ (បានរៀបចំចំនុចវិវាទ និងភស្តុតាងត្រូវបញ្ជាក់) តុលាការត្រូវកំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅភាគីមកចូលរួម ម.១១៣ ។

## ផ្នែកទី៣: ការទាញហេតុផលផ្ទាល់មាត់

១. ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់

- ដើម្បីស្តាប់ការអះអាងដោយផ្ទាល់ ដោយផ្អែកលើគោលការណ៍ចំពោះមុខ និងគោលការណ៍ជម្រះក្តីជាសាធារណៈ និងការឆ្លើយតបទៅនឹងការអះអាងរបស់ភាគីម្ខាងទៀត មុនពេលចេញសាលក្រមម.១១៤/១
- ដើម្បីធានាឲ្យមានប្រសិទ្ធិភាពនូវសិទ្ធិទាមទារឲ្យមានការសាកសួរ គូភាគីគួរមានវត្តមាននៅកាលបរិច្ឆេទនីមួយៗ និងចំពោះមុខគ្នាទៅវិញទៅមក ម.១១៥/១ និងនៅសាលសវនាការជាសាធារណៈ ម.១១៥/២ ប៉ុន្តែអាចអសាធារណៈ ករណីមានការខូចខាតដល់សណ្តាប់ធ្នាប់សាធារណៈ។

២. កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់

២.១ ការសាកល្បងផ្សះផ្សា

- ម.៩៧: ការផ្សះផ្សា អាចធ្វើនៅគ្រប់ដំណាក់កាលណាក៏បាន។

២.២ សេចក្តីថ្លែងការអំពីលទ្ធផលត្រៀមសម្រាប់ការទាញហេតុផល

- ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍ អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ម.១១៦/១។ សេចក្តីថ្លែងការណ៍ ត្រូវបញ្ជាក់ឲ្យច្បាស់លាស់អំពីអង្គហេតុ ដែលនឹងបញ្ជាក់អំពី

ការពិនិត្យភស្តុតាង មានន័យថាជាចំនុចវិវាទ ដែលត្រូវធ្វើពេលទាញហេតុផលដោយផ្ទាល់មាត់ ម.១១៦/២។

- សេចក្តីថ្លែងការណ៍អាចធ្វើដោយភាគីណាក់បាន ឬអ្នកតំណាងដោយអាណត្តិ ឬចៅក្រមផ្ទាល់។

២.៣ <u>ការពិនិត្យភស្តុតាងដោយសម្ភូហាវិធី</u>

- នៅកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចធ្វើការពិនិត្យភស្តុតាង ដោយសម្ភូហាវិធី ម.១២៧/២ ដូចជា : *ការសាកសួរសាក្សី , សាមីភាគី* ជាដើម។
- តាមរយៈការពិនិត្យភស្តុតាងដោយសម្ភូហាវិធី តុលាការអាចនឹងធ្វើការវិនិច្ឆ័យបានត្រឹមត្រូវ ហើយបានលឿនផ្អែកលើជំនឿទុកចិត្តដោយសេរី។

២.៣.១ <u>ការសាកសួរសាក្សី</u>

- គឺសាកសួរទៅលើសាក្សីណាដែលមានក្នុងពាក្យស្នើសុំ រួមទាំងសំនួរដែលភ្ជាប់ជាមួយ
- សាក្សីត្រូវធ្វើសម្បថ មុននឹងសាកសួរ ម.១៣៧
- ការសាកសួរសាក្សីត្រូវធ្វើតាមលំដាប់: ប្រធានក្រុមប្រឹក្សា, ភាគីដែលបានស្នើសុំ, ភាគីម្ខាងទៀត ម.១៣៨/៥ ប៉ុន្តែតុលាការក៏អាចផ្លាស់ប្តូរលំដាប់នៃការសួរសាក្សីបាន ម.១៣៨/៦ និងកំរិតសំនួរលើសាក្សី ម.១៣៩។

២.៣.២ <u>ការសាកសួរសាមីភាគី</u>

- នីតិវិធីនៃការសាកសួរភាគី ដូចនឹងការសាកសួរសាក្សីដែរ ម.១៤១/១ ចំនុចខុសគ្នាត្រង់ភាគីពុំមានកាតព្វកិច្ចស្បថទេ តែតុលាការក៏អាចឲ្យភាគីធ្វើសម្បថ តាមឆន្ទានុសិទ្ធិបាន ម.១៤០/១។
- សេចក្តីថ្លែងការណ៍ក្នុងការសាកសួរសាមីភាគី គឺជាសកម្មភាពរៀបរាប់ដោយភាគីជូនតុលាការ នូវអ្វីៗដែលខ្លួនជួបប្រទះពីមុន ដែលបញ្ជាក់ពីអង្គហេតុ ហើយត្រូវចាត់ទុកថាជាភស្តុតាងដូចសេចក្តីថ្លែងការណ៍ជាភស្តុតាងរបស់សាក្សីដែរ ដែលវាមានលក្ខណៈខុសពីការអះអាងរបស់ភាគី មិនមែនជាភស្តុតាងទេ គ្រាន់តែជាការបង្ហាញចំពោះតុលាការ នូវអង្គ

ហេតុ ដែលជាមូលដ្ឋាននៃអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលទាមទារតាមផ្លូវបណ្តឹងប៉ុណ្ណោះ។

២.៣.៣ កោសលវិច័យ ម.១៤០

- ជាភស្តុតាងមួយប្រភេទតាមរយៈការស្នើសុំរបស់ភាគី ឬ តាមឆន្ទានុសិទ្ធិចៅក្រម ម.១២៤។
- ជាការបង្គាប់ឱ្យតតិយជន ដែលមានឯកទេស បច្ចេកទេស និងចំណេះដឹង ឱ្យធ្វើការវិនិច្ឆ័យលើចំនុចណាមួយដោយផ្អែកលើ ឯកទេស បច្ចេកទេស និង ចំណេះដឹងនោះ។
- តុលាការជាអ្នកជ្រើសតាំងអ្នកធ្វើកោសលវិច័យដោយសមភាព ម.១៤៤ និង ម.១៤៥។

២.៣.៤ ភស្តុតាងជាឯកសារ ម.១៤៨

- ភស្តុតាងជាឯកសារនេះ តុលាការបានពិនិត្យរួចហើយក្នុងកំរិតដែលចាំបាច់ ដើម្បីរៀបចំចំណុចវិវាទនៅ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ម.១០៦ ដូច្នេះក្នុងតំណាក់កាលនេះ មិនសូវមានសារៈសំខាន់ទេ ដើម្បីត្រួតពិនិត្យម្តងទៀត។
- បើភាគីស្នើសុំឱ្យពិនិត្យក្នុង នីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវធ្វើការពិនិត្យម្តងទៀតបាន។

២.៣.៥ ការត្រួតពិនិត្យ ម.១៦១

- គឺជាការពិនិត្យភស្តុតាងដើម្បីទទួលបាននូវធនធានភស្តុតាង ដោយការត្រួតពិនិត្យនូវភិនភាគដោយផ្ទាល់ពីចៅក្រម ដោយប្រើវិញ្ញាណទាំង៥។

២.៤ ការបញ្ចប់នីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់

- បើយល់ឃើញថាត្រូវបញ្ចប់ការវិនិច្ឆ័យដោយផ្អែកលើលទ្ធផល នៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយចេញសាលក្រមចុងក្រោយ ម.១៨០/២។ ការបញ្ចប់នេះធ្វើឱ្យអាជ្ញាអស់ជំនុំនៃការវិនិច្ឆ័យ ត្រូវកំណត់ជាស្ថាពរនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត នាពេលបញ្ចប់នេះ ម.១៩៤។
- តុលាការអាចឱ្យភាគីនីមួយៗធ្វើការទាញហេតុផលចុងក្រោយ មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ម.១១៦/៥។ ការទាញហេតុផលចុងក្រោយត្រូវធ្វើក្រោយការពិនិត្យភស្តុតាង

ហើយភាគីនីមួយៗត្រូវសរសេរពន្យល់ឲ្យតុលាការយល់ដឹងឲ្យបានពេញលេញនូវអង្គហេតុ តាមរយៈការពិនិត្យភស្តុតាង។

- ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់ ចំនុចជារូបមន្ត និងចំនុចជាសារធាតុ ម.១១៨ និង ម.១១៩។

## ផ្នែកទី៤: នីតិវិធីបញ្ចប់ការដោះស្រាយបណ្តឹង

➢ <u>មូលហេតុ</u>

- គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន
- ការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ (ភាគីម្ខាងមរណភាព, ការរួមបញ្ចូលនូវឋានៈភាគីទាំង២)
- ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី (ការដកពាក្យបណ្តឹង, ការទទួលស្គាល់, ការលះបង់, ការសះជា)
- ការបញ្ចប់បណ្តឹងដោយសកម្មភាពតុលាការ (នីតិវិធីបណ្តឹងរហូតចេញសាលក្រមចុងក្រោយ)។

### ១. ការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ

- ករណីដែលភាគីម្ខាងទទួលមរណភាព ហើយគ្មានអ្នកបន្តសិទ្ធិ និងករណីកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង។ ធម្មតាទោះបីជាភាគីម្ខាងទទួលមរណភាពក៏ដោយ សន្តតិជននឹងទទួលបន្តនីតិវិធីបណ្តឹង (នីតិវិធីបណ្តឹងធម្មតា) តែក៏មានករណីពុំមានអ្នកទទួលបន្តនូវនីតិវិធីបណ្តឹងដោយសារលក្ខណៈនៃសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនោះ។ <u>ឧទាហរណ៍:</u> ករណីបណ្តឹងសុំលែងលះ ភាគីម្ខាងទទួលមរណភាព ⟶ គ្មានអ្នកទទួលបន្ត។

- ករណីភាគីម្ខាងទទួលមរណភាព ឬ បានរលត់ដោយសារការរួមបញ្ចូលនូវនីតិបុគ្គល ហើយសិទ្ធិ ឬ កាតព្វកិច្ចដែលកម្មវត្ថុនៃបណ្តឹងធ្លាក់ទៅលើបុគ្គលតែម្នាក់។ នេះជាករណី ដែលចុងចម្លើយបានក្លាយជាដើមចោទ ដោយសារតែភាគីម្ខាងបានទទួលបន្តនូវឋានៈតាមផ្លូវបណ្តឹងរបស់ភាគីម្ខាងទៀត ដោយសារសន្តតិកម្ម ឬការរួមបញ្ចូលគ្នានីតិបុគ្គល។ <u>ឧទាហរណ៍:</u> ការទិញភាគហ៊ុនជាដើម។

### ២. ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី

ក. <u>ការដកពាក្យបណ្តឹង</u>

១. <u>អត្ថន័យ</u> (ម.២១៧/១)

• សកម្មភាពដកមួយភាគ ឬ ទាំងស្រុង នូវពាក្យសុំទាមទារឲ្យចេញសាលក្រមតាមរយៈបណ្ដឹងរបស់ដើមចោទ

• ការដកធ្វើទៅតាមឆន្ទៈរបស់ភាគីដើមចោទតែប៉ុណ្ណោះ។

២. <u>លក្ខខណ្ឌ និងវិធីដក</u>

- ដកពេលណាក៏បាន ម.២១៧/១
- មានការយល់ព្រមពីចុងចម្លើយ (ករណីចុងចម្លើយបានដាក់ឯកសារត្រៀមនៅតំណាក់កាលត្រៀម និងការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ) ម.២១៧/២
- ធ្វើជាលាយលក្ខអក្សរ ម.២១៧/៣
- ចុងចម្លើយមិនតវ៉ាក្នុងអំឡុងពេល ២សប្ដាហ៍ ចាត់ទុកថាចុងចម្លើយយល់ព្រមឲ្យដកពាក្យបណ្ដឹង ម.២១៧/៥
- សមត្ថភាពធ្វើបណ្ដឹង ម.៣៣/២.ក និង ម.៥៤/១និង៣។

៣. <u>អានុភាពដកពាក្យបណ្ដឹង</u> ម.២១៨

- ផ្នែកដែលត្រូវបានដកត្រូវចាត់ទុកថា មិនបានចាត់ការតាំងពីដំបូង ម.២១៨/១
- ភាគីដកពាក្យបណ្ដឹងក្រោយចេញសាលក្រមចុងក្រោយ មិនអាចដាក់បណ្ដឹងដូចគ្នាម្ដងទៀតទេ ម.២១៨/២។

ខ. <u>ការសះជាតាមផ្លូវបណ្ដឹង</u> ម.២២០

១. <u>អត្ថន័យ</u>

- សកម្មភាពដើមចោទ និងចុងចម្លើយ ធ្វើសម្បទានគ្នាទៅវិញទៅមក នូវការអះអាងពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹង ហើយព្រមបញ្ចប់វិវាទក្នុងនីតិវិធីបណ្ដឹងដោយធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនោះ ដោយឯកភាពគ្នាចំពោះមុខតុលាការ (ម.៩៧, ម.១០៤, ម.២២០ និង ម.២២២)។

២. <u>ផលប្រយោជន៍</u>

- ចំណេញពេលវេលា

- ទទួលខ្លឹមសារនៃការសះជាសមរម្យ ស្របនឹងលក្ខណៈ និងស្ថានភាពនៃរឿងក្តី
- ភាគីអនុវត្តដោយស្ម័គ្រចិត្ត នូវកាតព្វកិច្ច ដែលបានសន្យាក្នុងការសះជា
- រក្សានូវស្ថានភាពប្រក្រតី នូវទំនាក់ទំនងរបស់ភាគីនាពេលអនាគត។

៣. ការផ្សះផ្សាក្រៅតុលាការ

- យោងតាម ម.៩៧
- ករណីភាគីទាំងសងខាង ឬ ម្ខាងមានបំណងផ្សះផ្សា ឬ តាមឆន្ទៈរបស់តុលាការ

៤. ការផ្សះផ្សានៅ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់ និងកាលបរិច្ឆេទផ្សះផ្សា

- នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល: ម.១០៤
- ការទាញហេតុផលដោយផ្ទាល់មាត់: ម.៩៧ និង ម.២២០
- កាលបរិច្ឆេទផ្សះផ្សា ម.២២០
- វិធីផ្សះផ្សា : បង្ហាញជំនឿទុកចិត្តពីភាគី។

៥. ការផ្សះផ្សាក្រៅតុលាការ

- ពាក់ព័ន្ធជម្លោះស្តីពីព្រំដី ឬ ការសាងសង់ ⟶ ផ្សះផ្សានៅកន្លែងនោះមើលស្ថានភាពជម្លោះជាក់ស្តែង
- ភាគីម្ខាងមានជំងឺជាទម្ងន់។

៦. អានុភាព

- កំណត់ហេតុមានអានុភាពដូចសាលក្រមស្ថាពរ ម.២២២
- ភាគីត្រូវអនុវត្តកាតព្វកិច្ចក្នុងកំណត់ហេតុសះជា
- បើមិនអនុវត្តទេ ⟶ អនុវត្តដោយបង្ខំ ម.៣៥០/២/ឈ
- គ្មានអាជ្ញាអស់ជំនុំទេ ⟶ កំណត់ហេតុមានវិការៈ

➢ បើការសះជាមានវិការៈ បណ្តឹងមិនទាន់បញ្ចប់ ⟶ ចេញសាលក្រមរបៀប ម.១៨១ ⟶ បន្តនីតិវិធីបណ្តឹង ⟶ ចេញសាលក្រមចុងក្រោយ ⟶ ប្តឹងឧបាស្រ័យ។

➢ បើការសះជាមានសុពលៈ ចេញសាលក្រមចុងក្រោយ ថាបណ្តឹងត្រូវបានបញ្ចប់ដោយការសះជា → មិនអាចប្តឹងឧបាស្រ័យបានទេ។

គ. <u>ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ</u> ម.២២១

១. <u>អត្ថន័យ</u>

- <u>ការលះបង់នូវការទាមទារ</u>: ជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងរបស់ចុងចម្លើយ ដែលទទួលស្គាល់ខ្លួនឯងថា ការទាមទារតាមផ្លូវបណ្តឹងរបស់ខ្លួន ពុំមានមូលហេតុត្រឹមត្រូវ មានន័យថា សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលខ្លួនបានអះអាងដោយបណ្តឹង គ្មានអត្ថិភាព។
- <u>ការទទួលស្គាល់ការទាមទារ</u>: ជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងរបស់ចុងចម្លើយ ដែលទទួលស្គាល់ដោយគ្មានលក្ខខណ្ឌថា ការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ មានមូលហេតុត្រឹមត្រូវ មានន័យថាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលដើមចោទអះអាងមានអត្ថិភាពទាំងស្រុង។

២. <u>លក្ខខណ្ឌ និងវិធីដក</u>

- ថ្លែងការណ៍ដោយផ្ទាល់ចំពោះមុខចៅក្រម នៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ម.៣ និង ម.២២១
- អំពីសមត្ថភាពរបស់ភាគី និងការតំណាង ម.៣៣/២.ក (ជនក្រោមហិត្ថបត្ថម្ភ) និង ម.៥៤/១,៣ (មេធាវី)
- អំពីការទាមទារ :
  - កុំឱ្យមានកង្វះនូវលក្ខខណ្ឌបណ្តឹង ព្រោះអានុភាពដូចសាលក្រមស្ថាពរ
  - ខ្លឹមសារនៃការទាមទារ ត្រូវជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដល់ភាគីដែលអាចចាត់ចែងសេរី។

៣. <u>ការបញ្ចប់បណ្តឹងដោយសកម្មភាពរបស់តុលាការ</u>

អនុវត្តដូចនីតិវិធីធម្មតា មាន ៣ ដំណាក់កាល :

១. នីតិវិធីដាក់ពាក្យបណ្តឹង

២. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

៣. នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ → សាលក្រមចុងក្រោយ។

# ផ្នែកទី៥: ការចាត់ចែងរក្សាការពារ

## គោលគំនិត: ម. ៥៣០

- មានការបារម្ភថា ការអនុវត្តដោយបង្ខំ នឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពនៃទ្រព្យសម្បត្តិរបស់កូនបំណុល ម.៥៣០។
- មានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ជាបន្ទាន់ ដល់ឋានៈរបស់ភាគីណាមួយ ដោយ សារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ ម.៥៣០។

## I. <u>ប្រភេទនៃការចាត់ចែងរក្សាការពារ</u>: ម.៥៣១

១. ការរឹបអូសជាបណ្ដោះអាសន្ន

- សិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់
- កម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ។

២. ការចាត់ចែងជាបណ្ដោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

- រក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ
- ករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុ។

៣. ការចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

- កំណត់ស្ថានភាពជាបណ្ដោះអាសន្ន រហូតដល់មានសាលក្រម ឬ សាលដីកា
- ករណីដែលមានភាពចាំបាច់ ដើម្បីចៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់ជាបន្ទាន់ ដែលនឹងកើតឡើងចំពោះម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។

## II. <u>នីតិវិធីនៃការចាត់ចែងរក្សាការពារ</u>

១. <u>សមត្ថកិច្ច</u>: ម.៥៤០

- សាលាដំបូងនាកន្លែងដែលវត្ថុ ឬ កម្មវត្ថុនៃវិវាទស្ថិតនៅ។ បើកម្មវត្ថុ គឺជាសិទ្ធិ:
  - សិទ្ធិលើបំណុលស្ថិតនៅកន្លែងកូនបំណុលទី៣ (ម.៨)
  - សិទ្ធិលើបំណុលមានកម្មវត្ថុជានាវា ឬ ចលនវត្ថុ សិទ្ធិលើបំណុលនៅកន្លែងវត្ថុនោះ។

- តុលាការមានសមត្ថកិច្ចលើអង្គសេចក្តី ម.៨, ម.៩, ម.១០,និង ម.១១: សាលាដំបូង ឬ សាលាឧទ្ធរណ៍។

២. ពាក្យសុំចេញដីកាសម្រេចរក្សាការពារ:

- ធ្វើជាលាយលក្ខណ៍អក្សរ ម.៥៣៤
- ចំនុចដូច ម.៥៤១: ឈ្មោះ អាសយដ្ឋាន ខ្លឹមសារ សិទ្ធិ និងទំនាក់ទំនងគតិយុត្តត្រូវការពារ និងភាពចាំបាច់នៃការរក្សាការពារ (ត្រូវសរសេរឲ្យច្បាស់លាស់នូវអង្គហេតុនីមួយៗ សេចក្តីបញ្ជាក់ដំបូង)។

៣. ប្រាតិភោគសម្រាប់ដីកា:

- តុលាការអាចឲ្យម្ចាស់បំណុលដាក់ប្រាតិភោគ ឬ មិនឲ្យដាក់ ដែលជាលក្ខខណ្ឌនៃការអនុវត្ត ម.៥៤២
- ប្រាតិភោគធ្វើតាមវិធីផ្ញើរប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ម.៥៣៦
- ចេញដីកាបង្គាប់ឲ្យដាក់ប្រាតិភោគ មុនចេញដីកាសម្រេចរក្សាការពារ
- ប្រាតិភោគសម្រាប់សងទៅកូនបំណុល

៤. នីតិវិធីនៃការសាកសួរ ឬ ធ្វើការទាញហេតុផលដោយផ្ទាល់មាត់:

- ការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ មិនចាំបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ គ្រាន់តែសួរម្ចាស់បំណុលអំពីសេចក្តីបញ្ជាក់ដំបូងបានហើយ ម.៥៣៩ និង ម១១៤។
- ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ត្រូវតែធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ម.៥៤៨ ឬ ការសាកសួរភាគីទាំងសងខាង។

៥. ការចេញដីកាសម្រេចរក្សាការពារ:

+ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ម.៥៤៥

- កំណត់ជាក់លាក់នូវវត្ថុរឹបអូស តែបើចលនវត្ថុ មិនកំណត់កម្មវត្ថុក៏បាន ម.៥៤៦/១ និង ២
- ត្រូវកំណត់នូវចំនួនទឹកប្រាក់រំដោះ ដើម្បីអោយកូនបំណុលរួចផុតពីការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ម.៥៤៧/១ ។

+ ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ម.៥៤៨ និង ម.៥៤៩

គឺទៅតាមកម្រិតនៃភាពចាំបាច់ដើម្បីសម្រេចគោលបំណងនៃពាក្យសុំចេញដីកាសម្រេច និងសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីផង ម.៦៥។

៦. ការបញ្ជូនដីកា:

- ត្រូវបញ្ជូនដីកាសម្រេចទៅភាគី ម.៥៤៣: បញ្ជូនទៅឲ្យម្ចាស់បំណុល → អនុវត្តដីកា → បញ្ជូនកូនបំណុលតាមក្រោយក៏បានដែរ ម.៥៦២/៣។

III. ការអនុវត្តដីកាសម្រេច

១. សមត្ថកិច្ច

- ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន
  - ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ម.៥៦៥ → អាជ្ញាសាលា។
  - ការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលនិងសិទ្ធិទ្រព្យសម្បត្តិផ្សេងទៀត ម. ៥៦៦
  - ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ម.៥៦៧
  - ការរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ម.៥៦៨

  (តុលាការអនុវត្ត — ម.៥៦៦, ម.៥៦៧, ម.៥៦៨)

- ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន: អនុវត្តដូចការរឹបអូសបណ្តោះអាសន្នដែរ ម.៥៧០,ម.៥៧១
  - អោយធ្វើ ឬមិនឲ្យធ្វើសកម្មភាពណាមួយ ម.៥២៧, ម.៥២៨, ម.៥៧០ → តុលាការអនុវត្ត
  - ហាមឃាត់ការផ្ទេរ, ការកាន់កាប់, ការចាត់ចែងអចលនវត្ថុ ម.៥៦៧,ម.៥៧០ → តុលាការអនុវត្ត
  - អោយប្រគល់វត្ថុ ម.៥២៤, ម.៥២៥, ម.៥៧០ និង ម.៥៧១ → អាជ្ញាសាលា។

២. ពាក្យសុំឲ្យអនុវត្តដីកាសម្រេចរក្សាការពារ

- ធ្វើជាលាយលក្ខណ៍អក្សរ ម.៥៣៤
- ដាក់ពាក្យសុំអនុវត្តក្នុងពេល ២សប្តាហ៍ គិតពីដីកាសម្រេចបញ្ជូនដល់ម្ចាស់បំណុល ម.៥៦២/២
- ចំនុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ ម.៣៤៩ និង ម.៥៦៤
- បង់សោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្តរក្សាការពារ ម.៥៣៧/២

- ភ្ជាប់លិខិតចម្លងយថាភូតនៃដីកាសម្រេច ម.៥៦២/១

- ករណីតតិយជន ត្រូវភ្ជាប់រូបមន្តអនុវត្តពិសេស ម.៥៦២/១.រ.២ ។

៣. <u>វិធីអនុវត្តរក្សាការពារ</u>

+ <u>ការរឹបអូសជាបណ្ដោះអាសន្នចំពោះ ចលនវត្ថុ</u>: ម.៥៦៥

- អាជ្ញាសាលាចាប់ផ្ដើមរឹបអូស ម.៣៣៥

- អាជ្ញាសាលាអាចឲ្យកូនបំណុលគ្រប់គ្រងនូវចលនវត្ថុដែលត្រូវរឹបអូស ដោយបិទស្លាក ឬ ដាក់សញ្ញារឹបអូស និងអាចឲ្យកូនបំណុលប្រើចលនវត្ថុបាន ម.៣៨៥/៤ និង ៣៨៥/៥

- បើរថយន្ត ឬ ទោចក្រយានយន្តចុះបញ្ជី អាជ្ញាសាលាត្រូវផ្ដុកផ្ដាក់ឲ្យស្ថាប័នមានសមត្ថកិច្ចសរសេរនូវហេតុការណ៍នៃការរឹបអូស ចូលក្នុងសៀវភៅចុះបញ្ជី ម.៣៨៧។

+ <u>ការរឹបអូសជាបណ្ដោះអាសន្នចំពោះ សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត</u>: ម.៥៦៦

- តុលាការចេញដីកាសម្រេចហាមឃាត់ មិនឲ្យកូនបំណុលទី៣ សងទៅកូនបំណុល ម.៤០៣/៥

+ <u>ការរឹបអូសជាបណ្ដោះអាសន្នចំពោះ អចលនវត្ថុ</u>: ម.៥៦៧

- តុលាការឲ្យក្រឡាបញ្ជីផ្ដុកផ្ដាក់ចុះបញ្ជីអចលនវត្ថុទៅសុរិយោដី ម.៤២០។

+ <u>ការរឹបអូសជាបណ្ដោះអាសន្នចំពោះ នាវា</u>: ម.៥៦៨

- តុលាការអនុវត្តបង្គាប់ឲ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ម.៤៥៧

- ឬ អោយក្រឡាបញ្ជីធ្វើការចុះបញ្ជី

- ឬ តាមវិធីទាំងពីរខាងលើ

+ <u>ការចាត់ចែងបណ្ដោះអាសន្ន ហាមឃាត់ការផ្ទេរ, ការកាន់កាប់, ការចាត់ចែងអចលនវត្ថុ</u>

- តុលាការអនុវត្ត: ក្រឡាបញ្ជីផ្ដុកផ្ដាក់ចុះបញ្ជី ម.៥៧០ និង ម.៥៦៧។

+ <u>ឲ្យបើកច្រកចេញចូល ឬ មិនឲ្យសាងសង់ (ធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ)</u>

- តុលាការអនុវត្ត : ក្រឡាបញ្ជីផ្ដុកផ្ដាក់ចុះបញ្ជី ម.៥៧០ ម.៥២៧ និង ម.៥២៨

៤. <u>ការផ្អាក និងការលុបចោលនូវការអនុវត្តរក្សាការពារ</u>:

ក. ការផ្អាក, ការលុបចោល ដោយមានបណ្ដឹងតវ៉ាចំពោះការទាមទារ, ការផ្ដល់រូបមន្ត, តតិយជន:

- បណ្ដឹងតវ៉ាចំពោះការទាមទាររបស់កូនបំណុល ម.៣៦៣ ⟶ ចេញសាលក្រម ម.៣៦៨ ហើយមានអានុភាពភ្លាម។
- បណ្ដឹងតវ៉ាចំពោះការទាមទារឱ្យផ្ដល់រូបមន្ត (ឱ្យតតិយជនធ្វើម្ចាស់បំណុល ឬ ធ្វើជាកូនបំណុល) ម.៣៦៤ ⟶ ចេញសាលក្រម ម.៣៦៨។
- បណ្ដឹងតវ៉ាចំពោះការទាមទាររបស់តតិយជន (ករណីអនុវត្តមកលើទ្រព្យសម្បត្តិរបស់ខ្លួន) ម.៣៦៥ ⟶ ចេញសាលក្រម ម.៣៦៧ និង ម.៣៦៨ ។
- មុននឹងតុលាការចេញសាលក្រមខាងលើ តុលាការអាចចេញដីកាសម្រេចផ្អាក ឬលុបចោលការចាត់ចែងការអនុវត្តដែលធ្វើរួចហើយ ឱ្យដាក់ប្រាតិភោគ ឬ មិនដាក់ប្រាតិភោគ ម.៣៦៧ ដីកាសម្រេចនេះមានអានុភាពផ្អាកតែ ២ខែ ប៉ុណ្ណោះ ម.៣៧០/២ ដូចច្នេះ តុលាការត្រូវសម្រេចបណ្ដឹងអង្គសេចក្ដីឱ្យបានមុនអំឡុងពេល ២ខែ។

ខ. <u>ការផ្អាក ឬ លុបចោល ដោយមានការដាក់ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្ត</u> :

- បើជាការចាត់ចែងរបស់ក្រឡាបញ្ជី ត្រូវដាក់ទៅតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅ។ តែបើជាការចាត់ចែងរបស់សារការី ត្រូវដាក់ពាក្យសុំពាក្យសុំតវ៉ាទៅសាលាដំបូង ដែលមានសមត្ថកិច្ចទីកន្លែងរបស់សារការីនោះស្ថិតនៅ ម.៣៦២។
- ការសម្រេចសេចក្ដី : តុលាការបង្គាប់ឱ្យផ្អាកដោយដាក់ប្រាតិភោគ ឬ មិនដាក់ ម.៣៦៩។

គ. <u>ការផ្អាក ឬ លុបចោល ការអនុវត្តតាមមាត្រា ម.៣៧០</u> :

ករណីមានឯកសារចម្លងយថាភូតនៃ:

ក.សេចក្ដីសម្រេចលុបចោលលិខិតអនុវត្ត ឬ លិខិតអនុវត្តភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

ខ.សេចក្ដីសម្រេច មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ

គ.សាលក្រម ឬ សាលដីកាស្ថាពរដែលថា ការផ្សះផ្សា ឬការទទួលស្គាល់ទាក់ទងលិខិតអនុវត្តគ្មានអានុភាព

ឃ.ឯកសារបញ្ជាក់ថាលិខិតអនុវត្ត (ចំនុច ខ ដល់ ង) ត្រូវបាត់បង់អនុភាព ដោយការដក ពាក្យបណ្ដឹង ឬ មូលហេតុផ្សេងទៀត

ង.កំណត់ហេតុអំពីការផ្សះផ្សា ដែលកំណត់ថាមិនអនុវត្តដោយបង្ខំ ឬ ដកពាក្យសុំឲ្យ អនុវត្តដោយបង្ខំនោះវិញ

ច. ឯកសារបញ្ជាក់ពីការដាក់ប្រាតិភោគ ដើម្បីឲ្យរួចផុតពីការអនុវត្តដោយបង្ខំ

ឆ. សេចក្ដីសម្រេចបង្គាប់ឲ្យផ្អាកការអនុវត្ត ឬ លុបចោលការចាត់ចែង

ជ. សេចក្ដីសម្រេច ដែលកំណត់ការបង្គាប់ឲ្យផ្អាកការអនុវត្តបង្ខំមួយរយៈ (២ខែ)

ឈ.ឯកសារដែលសរសេរថា ម្ចាស់បំណុលទទួលសំណង ឬ បានយល់ព្រមពន្យារពេល ត្រូវ សងនៅក្រោយ ពេលលិខិតអនុវត្តត្រូវបានបង្កើត។

ឃ. ពាក្យសុំផ្អាក ឬ សុំលុបចោលរបស់កូនបំណុលតាម: ម.៥៥២

- ដោយមានមូលហេតុៈ កូនបំណុលបានដាក់ពាក្យសុំតវ៉ា ចំពោះដីកាសម្រេចការពាររួចហើយ ម.៥៥០។

- សេចក្ដីបញ្ជាក់ដំបូង
  ១. មូលហេតុនៃការលុបចោលៈ គ្មានសិទ្ធិលើបំណុល ឬ មិនដាក់ បណ្ដឹងអង្គសេចក្ដី។
  ២. មានការបារម្ភថា ការខូចខាតមិនអាចសងបាន ដោយសារ ការអនុវត្តរក្សាការពារ។

## IV. បណ្ដឹងឧបាស្រ័យ

១. ការតវ៉ាចំពោះដីកា

- កូនបំណុលដាក់ពាក្យសុំតវ៉ាទៅតុលាការរក្សាការពារ តែពុំមានកំណត់អំឡុងពេលនៃការដាក់ពាក្យ សុំតវ៉ាទេ (កូនបំណុលអាចដាក់បានច្រើនដង) ម.៥៥០។
- ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទសួរភាគីទាំងសងខាង អាចចូលរួមបាន ម.៥៥២។
- តុលាការសម្រេចបញ្ចប់ការវិនិច្ឆ័យ ឬ អាចប្រកាសភ្លាមៗថាបញ្ចប់ការវិនិច្ឆ័យ ម.៥៥៣។

- ចេញដីកាសម្រេចអំពីពាក្យសុំតវ៉ា ដោយឲ្យកូនបំណុលដាក់ ឬមិនដាក់ប្រាតិភោគ ម.៥៥៤/១.២ ។
    - <u>ទទួលស្គាល់ ឬ ផ្លាស់ប្តូរ ឬ លុបចោល</u> ⟶ បង្គាប់ឲ្យម្ចាស់បំណុលបង្វិលវត្ថុ របស់កូនបំណុលមកវិញតាមរយៈ ដីកាសម្រេចបង្គាប់ឲ្យធ្វើបដិទាន ម.៥៥៥។
- ដីកាសម្រេចអំពីពាក្យសុំតវ៉ា ពុំមានអានុភាពទេ បើមិនទាន់ចូលស្ថាពរ ម.៥៥៦/១ តែអាចមានអានុភាពភ្លាម (ករណីពិសេស) ម.៥៥៦/២
- បញ្ជូនដីកាសម្រេចទៅភាគី ម.៥៥៤/៣។

២. <u>ការលុបចោលដីកា</u>

+ <u>ការលុបចោលដោយសារការមិនដាក់បណ្តឹងអង្គសេចក្តី</u>: ម.៥៥៧

- តុលាការបង្គាប់ឲ្យម្ចាស់បំណុលដាក់បណ្តឹងអង្គសេចក្តីក្នុងអំឡុងពេល មិនតិចជាង ២សប្តាហ៍
- តុលាការលុបចោលដីកា តាមពាក្យសុំរបស់កូនបំណុល។

+ <u>ការលុបចោល ដោយសារការផ្លាស់ប្តូរស្ថានភាព</u>: ម.៥៥៨

- ការរលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលត្រូវបានរក្សាការពារ
- ការរលត់ភាពចាំបាច់ក្នុងការរក្សាការពារ
- ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព

+ <u>ការលុបចោលការចាត់ចែងជាបណ្តោះអាសន្នដោយស្ថានភាពពិសេស</u>: ម.៥៥៩

- ការបារម្ភការខូចខាតដែលមិនអាចសង នឹងកើតឡើង
- ស្ថានភាពពិសេសផ្សេងទៀត

៣. <u>បណ្តឹងជំទាស់</u>: ម.៥៦១ រយៈពេល២សប្តាហ៍ ធ្វើឡើងចំពោះ:

- ដីកាសម្រេចលើកចោលពាក្យសុំឲ្យចេញដីកាសម្រេចរក្សាកាពារ ម.៥៤៤
- ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីការក្សាការពារ ឬ ពាក្យសុំឲ្យលុបចោលដីកា ៥៦១/១.ក
- ដីកាសម្រេចបង្គាប់ឲ្យធ្វើបដិទាន ម.៥៦១/១.ខ
- សេចក្តីសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ដែលធ្វើឡើងដោយតុលាការបណ្តឹងជំទាស់ពុំអាចប្តឹងជំទាស់បានឡើយ ម.៥៦១/១ (ករណីដីកាសម្រេចរក្សាការពារចេញ

ដោយសាលាឧទ្ធរណ៍ មិនអាចប្ដឹងជំទាស់ទៅតុលាការកំពូលបានទេ)។

៤. ការសុំឲ្យជំនុំជម្រះសារជាថ្មី

- ដីកាសម្រេចដែលអាចប្ដឹងជំទាស់ (ម.៥៦១) ហើយចូលជាស្ថាពរ អាចប្ដឹងសុំឲ្យជំនុំជ្រះសារជាថ្មីបាន ម.៣១៧
- មូលហេតុកំណត់ក្នុង ម.៣០៧ និង ម.៣០៨។

មូលហេតុ ម.៣០៧ ៖

ក.បើពុំបានចាត់តាំងតុលាការដែលបានចេញសាលក្រម ឬ សាលដីកាទៅតាមច្បាប់កំណត់

ខ.បើចៅក្រម ដែលពុំអាចចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកាតាមច្បាប់ បានចូលរួមនៅក្នុងការងារសាលក្រម ឬ សាលដីកានោះ។

គ.បើខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្ដឹង ឬ ខ្វះសិទ្ធិតំណាងដោយអាណត្តិ

ឃ.បើចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកា បានប្រព្រឹត្តបទល្មើសដែលពាក់ព័ន្ធនឹងមុខងាររបស់ខ្លួនចំពោះរឿងក្ដី។

ង.បើភាគីត្រូវបានសារភាព ឬ ត្រូវបានរាំងក្នុងការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ដែលមានឥទ្ធិពលដល់សាលក្រម ឬ សាលដីកា ដោយសារបទល្មើសរបស់អ្នកដទៃ។

ច.បើឯកសារ ឬ វត្ថុផ្សេងទៀត បានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា ត្រូវបានក្លែង ឬ កែប្រែដោយបន្លំ

ឆ.បើសេចក្ដីថ្លែងការណ៍មិនពិតរបស់សាក្សី អ្នកធ្វើកោសលវិច័យ អ្នកបកប្រែ ភាគី ដែលបានធ្វើសម្បថ ឬ របស់អ្នកដំណាងដែលច្បាប់បានកំណត់ ដែលបានធ្វើសម្បថ បានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា។

ជ.បើសាលក្រម ឬ សាលដីកា ឬ សេចក្ដីសម្រេចផ្សេងទៀត ផ្នែករដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ ឬ ការចាត់ចែងផ្នែករដ្ឋបាល ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកាត្រូវបានផ្លាស់ប្ដូរ ដោយសារសេចក្ដីសម្រេច ឬ ការចាត់ចែងផ្នែករដ្ឋបាលនៅពេលក្រោយ។

ឈ.បើមានការភ្លេចបញ្ចូលសេចក្តីវិនិច្ឆ័យលើចំនុចសំខាន់ៗ ដែលអាចមានឥទ្ធិពល ទៅលើសាលក្រម ឬ សាលដីកា

ញ.បើសាលក្រម ឬ សាលដីកា ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារ ឲ្យជំនុំជម្រះសារជាថ្មីមានការប៉ះពាល់សាលក្រម ឬ សាលដីកាមុន ដែលបានចូលជាស្ថាពរហើយ។

<u>មូលហេតុ ម.៣០៨</u> :

ក្នុងករណីដែលមានមូលហេតុ ដូចបានកំណត់ក្នុង កឋាខណ្ឌ១ ម.៣០៧ ខាងលើនេះ សេចក្តីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ទោះជាមានកំណត់នូវមធ្យោបាយនៃឧបាស្រ័យដោយឯកឯង ចំពោះសេចក្តីសម្រេចនេះក៏ដោយ ក៏ភាគីអាចយកមូលហេតុនោះ មកធ្វើជាមូលហេតុនៃការជំនុំជម្រះសារជាថ្មី ចំពោះសាលក្រម ឬ សាលដីកានោះបានដែរ។ (និយាយតែពីភាពមិនប្រក្រតី ចំនុច ជ ផ្នែករដ្ឋបាលឯកសារតែប៉ុណ្ណោះ)។

# ផ្នែកទី ៦: នីតិវិធីអនុវត្តដោយបង្ខំ

## I. លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ

### ១. លិខិតអនុវត្ត (និយមន័យ)

លិខិតអនុវត្ត គឺជាឯកសារដែលមានបញ្ជាក់ពីអត្ថិភាព និងទំហំនៃសិទ្ធិទាមទារ ដែលត្រូវអនុវត្តដោយការអនុវត្តដោយបង្ខំ។ ក្នុងករណីដែលសិទ្ធិទាមទារ បានសរសេរនៅក្នុងលិខិតអនុវត្ត អាចអនុវត្តដោយបង្ខំតាមការបង្ខំដោយផ្ទាល់មាត់បាន។

### ២. ប្រភេទនៃលិខិតអនុវត្ត

ក. <u>សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្ដល់តាវកាលិកចូលជាស្ថាពរ</u>:

សាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរអាចអនុវត្តបាន ចាប់តាំងពីពេលដែលអាជ្ញាអស់ជំនុំកើតឡើង ម.១៩៥ ហើយរាប់បញ្ចូលផងដែរនូវសាលក្រម ឬ សាលដីកាព្រហ្មទណ្ឌ ដែលទទួលស្គាល់ការទាមទារផ្នែករប្បវេណី។

ខ. <u>សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្ដល់តាវកាលិក ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន</u>:

ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នក៏មានបញ្ញត្តិក្នុងក្រមនីតិវិធីរប្បវេណីដែរ ចំពោះសាលក្រមដែលសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ បើយល់ឃើញថាចំបាច់ តុលាការអាចប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នបានដោយឱ្យដើមចោទដាក់ប្រាតិភោគ ឬ មិនដាក់ តាមពាក្យសុំ ឬ ឆន្ទានុសិទ្ធិរបស់ខ្លួន ម.១៩៦។

គ. <u>ដីកាសម្រេចបង្គាប់ឱ្យផ្ដល់តាវកាលិក</u>:

ដីកាសម្រេចនេះ មានអានុភាពទាល់តែចូលជាស្ថាពរ។ ដូចជាដីកាសម្រេចបង្គាប់ឱ្យប្រគល់នាវា ម.៤៨៣, ដីកាបង្គាប់ឱ្យប្រគល់អចលនវត្ថុដែលក្ងបំណុលបានកាន់កាប់ប្រគល់ទៅឱ្យអ្នកទិញ តាមពាក្យសុំរបស់អ្នកទិញដែលបង់ថ្លៃលក់ហើយ ម.៤៥០ ជាដើម។ ជាគោលការណ៍ ដីកាសម្រេចនឹងមានអានុភាព លុះត្រាតែបានជូនដំណឹង តាមវិធីដែលអាចទទួលស្គាល់ថាសមរម្យ ម.២១៣។

ឃ. <u>ដីកាសម្រេចដាស់តឿន ដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តបណ្ដោះអាសន្ន</u>:

ក្នុងនីតិវិធីដាស់តឿន តុលាការអាចចេញដីកាសម្រេចដាស់តឿន ដោយប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

បាន ម.៣២៨។

ង. ការចាត់ចែងរបស់ក្រឡាបញ្ជី:

ទាក់ទងទៅនឹងនីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី ម.៦៦/១។

ច. លិខិតយថាភូតដែលធ្វើដោយសារការី:

ចំពោះការទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់មានកំណត់ ប៉ុន្តែទាល់តែមានសេចក្តីថ្លែងការណ៍បញ្ជាក់ក្នុងលិខិតនោះថា កូនបំណុលនឹងទទួលយកការអនុវត្តដោយបង្ខំភ្លាមៗ។ ដូចជាក្នុងករណី: កិច្ចសន្យាខ្ចីប្រាក់ដែលធ្វើជាលិខិតយថាភូតដោយសារការី នៅពេលមានវិវាទកើតឡើង អាចយកលិខិតនោះទៅអនុវត្តបាន។

ឆ. សាលក្រម ឬ សាលដីការបស់តុលាការបរទេស:

ទាល់តែមានសាលក្រមអនុវត្តបានចូលជាស្ថាពរ ម.៣៥២។

ជ. សេចក្តីសម្រេចមជ្ឈត្តករ:

ទាល់តែមានដីកាសម្រេចអនុវត្តចូលជាស្ថាពរ ម.៣៥៣។

ឈ. កំណត់ហេតុ:

ដែលមានចែងក្នុង ម.២២២ (*អានុភាពកំណត់ហេតុស្តីពីការសះជា*) និងកំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាស្ថាពរ។

*ដីកាសម្រេចរក្សាការពារ* គឺជាប្រភេទមួយស្ថិតនៅក្នុងនីតិវិធីអនុវត្តដោយបង្ខំផងដែរ ម.៥៦៤ ។

## II. ស្ថាប័នអនុវត្ត

ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត តាមពាក្យសុំរបស់ភាគី ម.៣៣៦/១។ ស្ថាប័នអនុវត្តមាន*តុលាការអនុវត្ត* និង *អាជ្ញាសាលា* ម.៣៣៦/២។

### ១. តុលាការអនុវត្ត:

តុលាការអនុវត្ត គឺជាសាលាដំបូងដែលមានសមត្ថកិច្ចក្នុងការអនុវត្តដោយបង្ខំ ម.២២៦/៣។ ក្រមនីតិវិធីរដ្ឋប្បវេណី មិនបានកំណត់អំពីតុលាការអនុវត្ត ថាតើជាចៅក្រមទទួលបន្ទុករឿងក្តី ឬ ចៅក្រមផ្សេងនោះទេ តែបើផ្អែកតាម ម.២៦ គឺប្រធានសាលាដំបូង ក្រោយពីប្រជុំស្តាប់យោបល់ពីចៅក្រមទាំងអស់ ត្រូវធ្វើដីកាសម្រេចបែងចែករឿងក្តីតាមលំដាប់នៅមុនរៀងរាល់ឆ្នាំ។

១.១ <u>សមត្ថកិច្ចរបស់តុលាការអនុវត្ត</u>

ក. <u>ការអនុវត្តដោយបង្ខំចំពោះ សិទ្ធិទាមទារមានគោលបំណងឲ្យសងជាប្រាក់</u>:

-ការអនុវត្តដោយបង្ខំចំពោះ<u>អចលនវត្ថុ</u>: ម.៤១៨ មានន័យថាតុលាការអនុវត្ត ធ្វើការអនុវត្តរឹបអូសអចលអនវត្ថុ ដី ផ្ទះ.... ដើម្បីប្តូរយកប្រាក់ទៅសងម្ចាស់បំណុល។ បើកម្មវត្ថុនៃការរឹបអូស ឬ អគារដែលបានចុះបញ្ជី តុលាការដែលមានសម្ថកិច្ចអនុវត្ត គឺសាលាដំបូងនាទីកន្លែងដែលដី ឬ អគារបានចុះបញ្ជី។ បើកម្មវត្ថុនៃការរឹបអូស ជាចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអគារដែលបានចុះបញ្ជី ឬសិទ្ធិជួលអចិន្ត្រៃយ៍ ផលលុបភោគ ដែលបានចុះបញ្ជី ឬ ចំណែកនៃសិទ្ធិទាំងនេះជាសិទ្ធិរួម តុលាការមានសមត្ថកិច្ច គឺសាលាដំបូងនាទីកន្លែងដែលបានចុះបញ្ជី។

-ការអនុវត្តដោយបង្ខំចំពោះ<u>សិទ្ធិលើបំណុល</u>: មានន័យថាជាការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ ឬ ប្រគល់ចលនវត្ថុណាមួយ ដែលប្រាក់ ឬ ចលនវត្ថុនោះត្រូវបានកាន់កាប់ដោយកូនបំណុលទី៣ ម.៤០២ និង ម.៤០៣។

-ការអនុវត្តដោយបង្ខំចំពោះ<u>នាវា</u>: សំដៅលើជលយានដែលមានចំណុះសរុប ≥ ២០តោន ទោះបីមិនបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា និង < ២០តោន បើបានចុះបញ្ជីនៅកម្ពុជា ម.៤៥៤ និង ម.៤៥៦។ ការអនុវត្តដោយបង្ខំចំពោះនាវា ត្រូវធ្វើដោយតុលាការអនុវត្តតាមវិធីលក់ដោយបង្ខំ ម.៤៥៥/១។

ខ. <u>ការអនុវត្តដោយបង្ខំ គ្មានគោលបំណងឲ្យសងជាប្រាក់</u>:

- ប្រគល់វត្ថុដែលកាន់កាប់ដោយតតិយជនឲ្យកូនបំណុល ម.៥២៦។ *ឧទាហរណ៍:* បង្គាប់អោយតតិយជនប្រគល់ឡានមកអោយកូនបំណុល ដើម្បីអោយកូនបំណុលប្រគល់ជូនអាជ្ញាសាលាមកគ្រប់គ្រងថែរក្សាវិញ។
- ការអនុវត្តចំពោះសិទ្ធិទាមទារឲ្យធ្វើសកម្មភាពណាមួយ។ *ឧទាហរណ៍:* ឲ្យកូនបំណុលរុះរើផ្ទះចេញ ម.៥២៧
- ការអនុវត្តចំពោះសិទ្ធិទាមទារមិនឲ្យធ្វើសកម្មភាពណាមួយ។ *ឧទាហរណ៍:* ហាមឃាត់កូនបំណុលមិនឲ្យសាងសង់ផ្ទះ ម.៥២៨ ។

១.២ <u>សិទ្ធិអំណាចផ្សេងទៀតរបស់តុលាការអនុវត្ត</u>

- តុលាការអនុវត្តធ្វើការអនុវត្តដោយមិនចុះដល់កន្លែងជាក់ស្តែងឡើយ។ ក្នុងករណី ដែលតុលាការអនុវត្តចាំបាច់ត្រូវចុះដល់ទីកន្លែង គឺមានស្ថាប័នជំនួយជាអ្នកចុះទីតាំងជាក់ស្តែង ម.៤៣៤/២។

- តុលាការអនុវត្ត ជាអ្នកត្រួតពិនិត្យមើលការអនុវត្តរបស់អាជ្ញាសាលា និងអ្នកជំនួយផ្សេងទៀត ម.៣៤០/១ និង ម.៣៤៤។

២. អាជ្ញាសាលា:

គឺជាស្ថាប័នអនុវត្តដោយបង្ខំ និងជាអ្នកជំនួយរបស់តុលាការអនុវត្ត ព្រមទាំងមានសមត្ថកិច្ចផ្សេងទៀត ដោយផ្អែកតាមច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត។

២.១ សមត្ថកិច្ចរបស់អាជ្ញាសាលា

ក. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឲ្យសងជាប្រាក់ :

- ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ: ពាក្យសុំអនុវត្តធ្វើទៅអាជ្ញាសាលា នៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំស្ថិតនៅ។ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រូវចាប់ផ្តើមដោយការរឹបអូសវត្ថុដែលជាកម្មវត្ថុដោយអាជ្ញាសាលា ម.៣៨៤/១ និង៣។

*ឧទាហរណ៍:* រឹបអូសម៉ូតូ១គ្រឿង ដើម្បីលក់ប្តូរយកប្រាក់សងបំណុល១លាន ។

ខ. ការអនុវត្តដោយបង្ខំគ្មានគោលបំណងឲ្យសងជាប្រាក់

- ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ: ប្រគល់អចលនវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀតដែលមានមនុស្សរស់នៅក្នុងនោះ ត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែង ដែលវត្ថុជាកម្មវត្ថុស្ថិតនៅ រំលាយការកាន់កាប់វត្ថុដែលជាកម្មវត្ថុរបស់កូនបំណុលនៃការអនុវត្ត ហើយធ្វើឲ្យម្ចាស់បំណុលនៃការអនុវត្តទទួលបានការកាន់កាប់នោះ ម.៥២៤។

*ឧទាហរណ៍:* សាលក្រមសម្រេចឲ្យកូនបំណុលនៃការអនុវត្ត ប្រគល់អគារឲ្យទៅម្ចាស់បំណុលនៃការអនុវត្ត។

- ការអនុវត្តដោយបង្ខំឲ្យប្រគល់ចលនវត្ថុ: ឲ្យប្រគល់ចលនវត្ថុក្រៅពីនាវា ឬ វត្ថុផ្សេងទៀតដែលមានមនុស្សរស់នៅក្នុងនោះ ត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ ដកយកចលនវត្ថុពីកូនបំណុលនៃការអនុវត្ត ហើយប្រគល់ចលនវត្ថុនោះ ទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត ម.៥២៥/១។

*ឧទាហរណ៍:* សាលក្រមសម្រេចឲ្យកូនបំណុលប្រគល់រថយន្តទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត។

## ២.២ សិទ្ធិ និងករណីកិច្ចរបស់អាជ្ញាសាលាក្នុងការអនុវត្តមុខនាទី

- ការធានាក្នុងការបំពេញមុខងាររបស់អាជ្ញាសាលា: ម.៣៣៨/១
  - ➢ ប្រើកំលាំង ឬ សុំជំនួយពីនគរបាល ឬ កងកំលាំងមានសមត្ថកិច្ច ដើម្បីបំបាត់ការប្រឆាំង។
- សិទ្ធិអំណាចក្នុងការចុះទៅទីតាំងផ្ទាល់ក្នុងការអនុវត្ត: ម.៣៨៥/២
  - ➢ ការអនុវត្តចលនវត្ថុ និងប្រគល់វត្ថុ អាជ្ញាសាលាត្រូវចុះដល់ផ្ទះរបស់កូនបំណុលនៃការអនុវត្ត។
- សិទ្ធិអំណាចជាស្ថាប័នជំនួយ: ម.៤៣៤/២ និង ៤៣៦/៣
  - ➢ ក្រៅពីបំពេញមុខនាទីជាស្ថាប័នអនុវត្តដោយបង្ខំ អាជ្ញាសាលាជាស្ថាប័នជំនួយ។
- ករណីកិច្ចយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ ម. ៣៤១
- ការអនុវត្តនៅថ្ងៃសម្រាក ឬ ពេលយប់ ម.៣៤០
  - ➢ ត្រូវទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ឬ តុលាការអនុវត្ត ដែលចេញការបង្គាប់ដើម្បីចូលទៅបំពេញមុខនាទី កន្លែងរស់នៅថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាក ពីម៉ោង ៦ល្ងាច ដល់ម៉ោង៦ព្រឹក នៃថ្ងៃបន្ទាប់។

## III. ស្ថាប័នជំនួយដល់ស្ថាប័នអនុវត្ត

១. ក្រឡាបញ្ជី: ក្រឡាបញ្ជី គឺជាជំនួយក្នុងការអនុវត្តដោយបង្ខំ របស់តុលាការអនុវត្ត។

- ម.៤២០: "បើដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំបានចេញ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឲ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូស ដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្តើមនោះជាបន្ទាន់" ។
- ម.៤៣៦/៤:"ពាក់ព័ន្ធនឹងការផ្សាយជាសាធារណៈនូវសញ្ញាណនៃអចលនវត្ថុ ដែលត្រូវលក់តម្លៃលក់អប្បបរមាព្រមទាំងកាលបរិច្ឆេទ និងទីកន្លែងលក់ ធ្វើឡើងដោយក្រឡាបញ្ជី" ។

២. អ្នកវាយតម្លៃ : ជាអ្នកជំនួយដែលតុលាការជ្រើសតាំង ដើម្បីបំពេញភារៈកិច្ចអនុវត្តដោយបង្ខំ។

- ម.៤៣០: តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកជំនាញ/អ្នកវាយតម្លៃ និងបង្គាប់ឲ្យវាយតម្លៃអចលនវត្ថុ ដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ និងទំនាក់ទំនងនៃការកាន់កាប់ និងស្ថានភាពបច្ចុប្បន្នផ្សេងទៀត។

៣. អាជ្ញាសាលា:

- ម.៤៣៤/២: " តុលាការអនុវត្ត អាចបង្គាប់ឲ្យអាជ្ញាសាលាស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ន នៃអចលនវត្ថុដូចជា៖ សណ្ឋាននៃចលនវត្ថុ ស្ថានភាពនៃការកាន់កាប់ វចនាសម្ព័ន្ធនៃអគារ ហើយត្រូវរាយការណ៍លទ្ធផលនៃការស្រាវជ្រាវនោះជាលាយលក្ខណ៍អក្សរ។ ក្រៅពីនេះអាជ្ញាសាលា ក៏ជាអ្នកអនុវត្តការលក់ផងដែរ ម.៤៣៦/ ៣ ។

៤. នគរបាល ឬ កំលាំងផ្សេងទៀត

- ម.៣៣៨/១: ប្រសិនបើអាជ្ញាសាលាជួបប្រទះនឹងការប្រឆាំង នៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលាអាចប្រើកំលាំង ឬ អាចសុំជំនួយពីនគរបាល ឬ កងកំលាំងផ្សេងទៀត ដែលមានសមត្ថកិច្ចដើម្បីបំបាត់ការប្រឆាំងនោះ។

៥. ក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ច

តុលាការអនុវត្តក៏អាចស្នើសុំជំនួយពីក្រសួង ឬ ស្ថាប័នមានសមត្ថកិច្ច ក្នុងការអនុវត្តដោយបង្ខំ ម.៣៤២។ ដូចជាករណីតម្លៃសារពើពន្ធលើរថយន្ត ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ តុលាការអាចស្នើសុំឲ្យក្រសួងមានសមត្ថកិច្ចចេញលិខិតបញ្ជាក់អំពីតម្លៃនៃសារពើពន្ធនោះ។

## IV. នីតិវិធីនៃការអនុវត្តដោយបង្ខំ

១. ប្រភេទនៃការអនុវត្ត

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត ម.៣៥០។ ភាគីដែលដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំហៅថា "ម្ចាស់បំណុលនៃការអនុវត្ត" ហើយភាគីម្ខាងទៀតហៅថា "កូនបំណុលនៃការអនុវត្ត" ម.៣៤៧។ ការអនុវត្តដោយបង្ខំ គឺធ្វើទៅតាមគោលបំណងនៃសិទ្ធិដូចជា:

ក. ចំពោះសិទ្ធិទាមទារ ដែលមានបំណងឲ្យសងជាប្រាក់

-ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ជាសមត្ថកិច្ចរបស់អាជ្ញាសាលា ម.៣៨៤ ដល់ ម.៤០១។

-ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ជាសមត្ថកិច្ចអនុវត្តរបស់តុលាការអនុវត្ត ម.៤០២ ដល់ ម.៤១៦។

-ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ជាសមត្ថកិច្ចរបស់តុលាការអនុវត្ត ម.៤១៧ ដល់ ម.៤៥៣។

-ការអនុវត្តដោយបង្ខំចំពោះនាវា ជាសមត្ថកិច្ចរបស់តុលាការ ម.៤៥៤ ដល់ ម.៤៨៦។

ខ. ចំពោះសិទ្ធិទាមទារ ដែលគ្មានគោលបំណងឱ្យសងជាប្រាក់

- ការអនុវត្តដោយបង្ខំឱ្យ ប្រគល់អចលនវត្ថុ ម. ៥២៤ } ជាសមត្ថកិច្ចរបស់អាជ្ញាសាលា
- ការអនុវត្តដោយបង្ខំឱ្យ ប្រគល់ចលនវត្ថុ ម. ៥២៥ }
- ការប្រគល់វត្ថុដែលកាន់កាប់ដោយ តតិយជន ម.៥២៦: ជាសមត្ថកិច្ចរបស់តុលាការអនុវត្ត។
- ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឲ្យ ធ្វើសកម្មភាព ឬ មិនធ្វើសកម្មភាពណាមួយ ម.៥២៧ និង ម.៥២៨ ជាសមត្ថកិច្ចរបស់តុលាការអនុវត្ត។

គ. ការអនុវត្តដោយបង្ខំចំពោះ សិទ្ធិប្រាតិភោគ

- ការអនុវត្តសិទ្ធិប្រាតិភោគ ចលនវត្ថុ ម.៥០០ ដល់ ម.៥០៤
- ការអនុវត្តសិទ្ធិប្រាតិភោគ អចលនវត្ថុ ម.៥០៩ ដល់ ម.៥២០
- ការអនុវត្តសិទ្ធិប្រាតិភោគ នាវា ម.៥២១ ដល់ ម.៥២៣
- ការអនុវត្តសិទ្ធិប្រាតិភោគ សិទ្ធិលើបំណុល និងទ្រព្យផ្សេងទៀត ម.៥០៥ ដល់ ម.៥០៨

២. ការចាប់ផ្តើមនអវុត្ត

នីតិវិធីការអនុវត្តមានគោលបំណងឲ្យសងប្រាក់ចំពោះ៖

ក. ចំពោះចលនវត្ថុ

- ក្រោយពីមានសាលក្រម ឬ សាលដីកាស្ថាពរហើយ ម្ចាស់បំណុលត្រូវដាក់ពាក្យសុំឲ្យផ្តល់រូបមន្ត ទៅក្រឡាបញ្ជី ឬ សារការី ( ម.៣៥០/២.ច) ដោយធ្វើជាលាយលក្ខណ៍អក្សរ ម.៣៥៥។
- ការផ្តល់រូបមន្ត ដោយក្រឡាបញ្ជី ឬ សាការី ម.៣៥៤
- ពាក្យសុំអនុវត្តដោយបង្ខំ ដាក់ទៅអាជ្ញាសាលា ម. ៣៨៤ → បញ្ជូនទៅកូនបំណុល
- ការបង់ពន្ធដាក់ពាក្យសុំ ម.៣៧២ និងសោហ៊ុយជាមុន ម.៣៧៥ ហើយក៏មានការបង់សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ ម.៣៧៣ និងសោហ៊ុយភាគី ម.៣៧៤។
- នៅពេលបង់ពន្ធរួចរាល់ហើយ អាជ្ញាសាលាទទួលរឿងក្តីយកមកចាត់ការតាមនីតិវិធី

- <u>ការរឹបអូស</u>: អាជ្ញាសាលា ត្រូវរឹបអូសវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ម.៣៨៤ ដោយមិនចាំបាច់មានដីកាសម្រេចចាប់ផ្តើមរឹបអូស ដូចក្នុងករណីអចលនវត្ថុទេ។
  - ការដាស់តឿនឱ្យកូនកំណុលនៃការអនុវត្តសងបំណុលដោយស្ម័គ្រចិត្ត: ប្រសិនបើជួបកូនបំណុលនៅកន្លែងរឹបអូស ត្រូវដាស់តឿនឱ្យកូនបំណុលសងបំណុលដោយស្ម័គ្រចិត្ត។
  - ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុល គឺត្រូវធ្វើតែចំពោះចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលប៉ុណ្ណោះ ម.៣៨៥។ អាជ្ញាសាលា អាចធ្វើការ ឆែកឆេរ បើកទូដែក......ជាដើម។
  - ការរឹបអូសវត្ថុដែលកាន់កាប់ដោយតតិយជន: ករណីនេះមិនអាចរឹបអូសវត្ថុនោះដោយបង្ខំ ដោយប្រើលិខិតអនុវត្តបានទេ លុះត្រាតែមានការយល់ព្រមពីតតិយជននោះ ម.៣៨៦។ ករណីតតិយជន មិនយល់ព្រមប្រគល់វត្ថុនោះឱ្យរឹបអូសទេ គឺមានតែយកសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ ដែលកូនបំណុលនោះមាន មកប្រើក្នុងនីតិវិធីអនុវត្តសិទ្ធិលើបំណុល ដើម្បីរឹបអូសយកវត្ថុនោះ ម. ៥២៦ ។
- <u>ការលក់</u>: ការលក់តាមវិធីលក់ឡាយឡុង ដោយផ្ទាល់មាត់ ឬដាក់ស្រោមសំបុត្រ ឬក៏ក្រៅពីវិធីនោះបានដោយមានការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ម.៣៩៥។ អាជ្ញាសាលាត្រូវជូនដំណឹង និងបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ ម.៣៩៥/៣។
  - ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់: ករណីរំខានពីជនណាម្នាក់ អាជ្ញាសាលាអាចដេញចេញ ឬមិនឱ្យស្នើសុំទិញបាន។
  - ការលក់ក្នុងពេលការអនុវត្តកំពុងត្រូវបានផ្អាក ម.៣៧០: អាជ្ញាសាលានៅតែអាចលក់ប្រសិនបើមានការបារម្ភថា តម្លៃលក់ចលនវត្ថុដែលរឹបអូសនឹងត្រូវចុះថោកខ្លាំង ឬ ប្រើសោហ៊ុយច្រើន ក្នុងការថែរក្សាទុក ហើយប្រាក់បានពីការលក់ ត្រូវផ្ញើទុកនៅសាលាដំបូងដែលខ្លួនស្ថិតនៅ ម.៣៧៩។
- <u>ការចែកចំណែក</u>
  - វិសាលភាពនៃបុគ្គលដែលត្រូវចែកចំណែក: ម.៣៩៨
    - ➢ ម្ចាស់បំណុលការអនុវត្ត
    - ➢ ម្ចាស់បំណុលដែលទាមទារចែកចំណែក រហូតដល់ពេលអាជ្ញាសាលា បានទទួលការប្រគល់ប្រាក់ពីការលក់

➢ ម្ចាស់បំណុលដែលទាមទារចែកចំណែក រហូតដល់ពេលអាជ្ញាសាលាបានរឹបអូសប្រាក់ ចំពោះប្រាក់ត្រូវរឹបអូស

- ការចែកចំណែកដោយអាជ្ញាសាលា: កំណត់អំឡុងពេល ២សប្តាហ៍ ជាថ្ងៃពិភាក្សាអំពីការចែកចំណែក។ អាជ្ញាសាលាចែកចំណែកអោយម្ចាស់បំណុលទាំងអស់ តែបើនៅសល់ប្រាក់ត្រូវសងទៅកូនបំណុលនៃការអនុវត្តវិញ។

- ការផ្ញើរប្រាក់ទុកនៅតុលាការដោយអាជ្ញាសាលា:

➢ សិទ្ធិបំណុលមានភ្ជាប់លក្ខខណ្ឌបង្អង់ ឬកំណត់ពេលមិនពិតប្រាកដ

➢ សិទ្ធិលើបំណុល ជាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្តោះអាសន្ន

➢ បើមានការដាក់ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចបង្គាប់ឲ្យផ្អាក ការអនុវត្តដោយបង្ខំមួយរយៈ។

➢ បើមានការដាក់ឯកសារចម្លងយថាភូត ដែលហាមឃាត់ការអនុវត្តមួយរយៈនៃឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំទាក់ទងនឹងសិទ្ធិលើបំណុល។

<u>លំហូរនីតិវិធី</u>:

ពាក្យសុំរូបមន្តអនុវត្ត → អាជ្ញាសាលា ឬ សារការី → ពាក្យសុំអនុវត្ត → ស្ថាប័នអនុវត្ត (អាជ្ញាសាលា) ការរឹបអូស → ការលក់ → ការចែកចំណែក → (អាជ្ញាសាលា ឬ សាលាដំបូង ករណីពិភាក្សាគ្នាមិនដាច់) ។

ខ. <u>ចំពោះអចលនវត្ថុ</u>

- សុំរូបមន្តអនុវត្ត → ផ្តល់រូបមន្តដោយក្រឡាបញ្ជី ឬ សារការី ម.៣៥៤ និង ម.៣៥៥
- ពាក្យសុំអនុវត្តដោយបង្ខំ → ពិនិត្យពីភាពត្រឹមត្រូវ ម.៣៤៩
- ដីកាសម្រេចបង់សោយហ៊ុយជាមុន ម.៣៧៥
- ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ម.៤១៩ → ជូនដំណឹងទៅភាគី ម.២១៣, ម.២៤៦ និង ម.៤១៩/២
- ក្រឡាបញ្ជីផ្ទុកផ្តាក់ចុះបញ្ជី ម.៤២០
- <u>ការរៀបចំលក់</u> : មុននឹងចាប់ផ្តើមលក់ តុលាការត្រូវធ្វើនីតិវិធី ៖
  - ដីកាបង្គាប់ឲ្យវាយតម្លៃ ម.៤៣០ → អ្នកវាយតម្លៃធ្វើរបាយការណ៍ស្តីពីការវាយតម្លៃ

- ដីការបង្គាប់ឲ្យស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ ម.៤៣៤ ⟶ របាយការណ៍
- តុលាការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យបែងចែកចំណែក និងប្រកាសជាសាធារណៈ
- ដាស់តឿនដល់ម្ចាស់បំណុលឲ្យរាយការណ៍ ម.៤២២ និងម្ចាស់បំណុលដែលមានសិទ្ធិទាមទារឲ្យចែកចំណែក ម.៤២៦ ⟶ ឯកសារលំអិតអំពីវត្ថុ ម.៤៣៤។

- <u>ការកំណត់អំពីលក្ខខណ្ឌលក់</u> :
  - ដីកាបង្គាប់ឲ្យវាយតម្លៃលក់អប្បបរមា ម.៤៣២
  - ដីកាសម្រេចបង្គាប់ឲ្យអនុវត្តការលក់ ម.៤៣៦
- វិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ⟶ ការជូនដំណឹង (ផ្សាយជាសាធារណៈ) ម.៤៣៦
  - កំណត់ហេតុស្តីពីការលក់ឡាយឡុងដោយស្រោមសំបុត្រ
  - ពាក្យសុំស្នើទិញ
- ដីកាសម្រេចលក់ ⟶ ធ្វើកំណត់ហេតុ
- <u>ការបង់ថ្លៃ</u>
  - ដីកាសម្រេចអំឡុងពេលសម្រាប់បង់ថ្លៃ ម.៤៤៧
  - សេចក្តីថ្លែងការណ៍អំពីការបង់ថ្លៃអចលនវត្ថុ
  - លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជី
- <u>ការបែងចែកចំណែក</u>
  - ដីកាសម្រេចអំពីពេលវេលាចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក ⟶ ជូនដំណឹង ម.៤២២
  - ដីកាសម្រេច អំពីការកំណត់កាលបរិច្ឆេទនៃការចែកចំណែក ម.៤៨៨
  - លិខិតដាស់តឿនឲ្យផ្តល់លិខិតគណនាអំពីសិទ្ធិលើបំណុល
  - កំណត់ហេតុស្តីពីការបែងចែកចំណែក
  - តារាងចែកចំណែក

## V. បណ្តឹងឧទ្ធរណ៍ស្រ័យ

### ១. ការតវ៉ាចំពោះការអនុវត្ត

#### ក. ការតវ៉ាចំពោះការចាត់ចែងអនុវត្តរបស់តុលាការអនុវត្ត: ម.៣៤៤/១

ចំពោះការចាត់ចែងអនុវត្តរបស់តុលាការអនុវត្ត ដែលមិនអាចប្តឹងជំទាស់បាន អាចតវ៉ាទៅតុលាការអនុវត្ត។ បើតុលាការចេញដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ ដីកានេះមិនអាចប្តឹងជំទាស់បាន ម.៤១៩ ប៉ុន្តែអាចប្តឹងតវ៉ាបាន ម.៣៤៤ → សម្រេចតាម → ម.៣៣៧។

#### ខ. ការតវ៉ាចំពោះការចាត់ចែងអនុវត្តរបស់អាជ្ញាសាលា : ម.៣៤៤/២

ចំពោះការចាត់ចែងអនុវត្តរបស់អាជ្ញាសាលា និងការយឺតយ៉ាវ ឬ ធ្វេសប្រហែស ក្នុងការចាត់ចែងអនុវត្ត អ្នកមិនសុខចិត្តអាចតវ៉ាទៅសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅបាន។

ករណីមានការតវ៉ាចំពោះការអនុវត្ត តុលាការអនុវត្ត ឬ សាលាដំបូងចេញដីកាសម្រេច ម.៣៣៧ មិនអាចប្តឹងជំទាស់។

(ម.៣៤៣/២)
- បង្គាប់ឲ្យផ្អាកអានុភាពនៃដីកាសម្រេចដើម ដោយដាក់ប្រាតិភោគ ឬ មិនដាក់ប្រាតិភោគ
- បង្គាប់ឲ្យផ្អាកនីតិវិធីនៃការអនុវត្តដោយបង្ខំមួយផ្នែក ឬ ទាំងមូលឲ្យដាក់ ឬមិនដាក់ប្រាតិភោគ។

### ២. បណ្តឹងជំទាស់

ជាប្រភេទមួយនៃបណ្តឹងឧទ្ធរណ៍ស្រ័យទៅតុលាការជាន់ខ្ពស់ ដែលជាតុលាការនៃបណ្តឹងជំទាស់ដើម្បីទាមទារឲ្យលុបចោល ឬ ផ្លាស់ប្តូរសេចក្តីសម្រេចដើម។ បណ្តឹងជំទាស់ ធ្វើបានលុះត្រាមានបញ្ញត្តិក្នុងច្បាប់ ម.២៥៩។ បណ្តឹងជំទាស់មិនផ្អាកអានុភាពនៃដីកាសម្រេចដើមឡើយ ម.៣៤៣/១ តែក្នុងអំឡុងពេលរហូតដល់សេចក្តីសម្រេចបណ្តឹងជំទាស់មានអានុភាព តុលាការបណ្តឹងជំទាស់ អាចចេញដីកាសម្រេចតាម ម.៣៤៣/២ ខាងលើបាន ។

### ៣. បណ្តឹងតវ៉ាចំពោះការទាមទារ

កូនបំណុលនៃការអនុវត្ត ដែលមានការតវ៉ាចំពោះអត្ថិភាពដែលកំណត់ក្នុងលិខិតអនុវត្ត អាចដាក់ពាក្យតវ៉ាចំពោះការទាមទារ ដើម្បីកុំឲ្យតុលាការអនុញ្ញាតការអនុវត្តដោយបង្ខំបាន ម.៣៦៣ ប៉ុន្តែចំពោះលិខិតអនុវត្ត ជា

សាលក្រម សាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកភ្ជាប់ជាមួយការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ឬ ដីកាសម្រេចដាស់តឿនភ្ជាប់ជាមួយការប្រកាសអនុវត្តជាបណ្តោះអាសន្ន បើមិនទាន់ស្ថាពរមិនអាចប្តឹងបានទេ។

៤. <u>បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្ត</u>

កូនបំណុលអាចតវ៉ាចំពោះការផ្តល់រូបមន្តពិសេស ម.៣៥៦ ឲ្យតតិយជនមកធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ ធ្វើជាកូនបំណុលនៃការអនុវត្តដោយ បង្ខំ ម.៣៦៤ → សម្រេច ម.៣៦៧។

៥. <u>បណ្តឹងតវ៉ារបស់តតិយជន</u> ម.៣៦៥ →សម្រេច ម.៣៦៨

តតិយជនអាចតវ៉ាចំពោះការអនុវត្តដោយបង្ខំមកលើទ្រព្យសម្បត្តិរបស់ខ្លួន ដែលខ្លួនជាម្ចាស់កម្មសិទ្ធិ ហើយធ្វើឲ្យបះពាល់ដល់ផលប្រយោជន៍របស់ខ្លួន។ តតិយជនអាចដាក់ពាក្យសុំផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ដោយដាក់ប្រាតិភោគ ឬមិនដាក់ ម.៣៦៧ និង ម.៣៤៣ ដើម្បីរងចាំដល់បណ្តឹងអង្គសេចក្តីស្ថាពរ។ ករណីតុលាការសម្រេចបណ្តឹងអង្គសេចក្តី សាលក្រមនោះមានអានុភាព ដោយការប្រកាសភ្លាម ម.៣៦៨ ហើយយកសាលក្រមនោះ ទៅលុបការអនុវត្តដោយបង្ខំ ម.៣៧០។

# ជំពូក ២

## នីតិវិធីព្រហ្មទណ្ឌខ្មែរ

## សម្រាប់អនុវត្តក្នុងរឿងក្តីព្រហ្មទណ្ឌ

## តាមសាលាជម្រះក្តីនានា

# ផ្នែកទី១: នគរបាលយុត្តិធម៌

## ១. នគរបាលយុត្តិធម៌:

ចែកចេញបីប្រភេទ៖ ម.៥៧

១- មន្ត្រីនគរបាលយុត្តិធម៌ (ម.ន.យ)

២- ភ្នាក់ងារនគរបាលយុត្តិធម៌ (ភ.ន.យ)

៣- មន្ត្រីរាជការ និង ភ្នាក់ងារសាធារណៈដែលទទួលបាននីតិសម្បទា។

## ២. និយមន័យ បទឧក្រិដ្ឋ ឬ មជ្ឈិមជាក់ស្តែង

<u>ជាក់ស្តែងពិត</u>: ម.៨៦:

- បទល្មើសកំពុងប្រព្រឹត្ត
- បទល្មើសទើបប្រព្រឹត្តរួចភ្លាម

ចាត់ទុកថា បទឧក្រិដ្ឋ ឬ មជ្ឈិមជាក់ស្តែង:

- ជនត្រូវដេញប្រធាប់ចាប់ប្រផឹង
- ជនមានជាប់ភស្តុតាងស៊ីសង្វាក់ (វត្ថុ ស្លាកស្នាម តម្រុយ)

<u>ចាត់ទុកដូចជា បទឧក្រិដ្ឋ ឬ មជ្ឈិមជាក់ស្តែង</u> ម.៨៨:

- អ្នកកាន់កាប់ទីកន្លែងកើតហេតុសុំឱ្យព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌មកពិនិត្យ (បើពុំមានមន្ត្រីនគរបាលយុត្តិធម៌ទេ ភ្នាក់ងារនគរបាលយុត្តិធម៌ អាចចុះមកពិនិត្យ តែត្រូវរាយការណ៍បន្ទាន់ទៅមន្ត្រីនគរបាលយុត្តិធម៌)។ ក្នុងករណីខាងលើ គ្រប់បុគ្គលទាំងអស់អាចចាប់បញ្ជូនជនល្មើសទៅ មន្ត្រីនគរបាលយុត្តិធម៌ ដែលនៅជិតបំផុត ។

## ៣. វិធានការណ៍ស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌

១. <u>បទឧក្រិដ្ឋ ឬ មជ្ឈិមជាក់ស្តែង</u>: ម.៨៩-ម.១១០

- រាយការណ៍ភ្លាមទៅព្រះរាជអាជ្ញា ពេលមានបទល្មើសកើតឡើង ម.៨៩
- ចុះទៅកាន់កន្លែងកើតហេតុដើម្បីពិនិត្យ និងប្រមូលភស្តុតាង ម.៨៩ (អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅឆ្ងាយ ពីកន្លែងកើតហេតុរហូតចប់ប្រតិបត្តិការរបស់ខ្លួន)
- កំណាត់ហេតុស្រាវជ្រាវ និង ពិនិត្យ ម.៩០

- មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរ (អនុវត្តតាមនីតិវិធីឆែកឆេរ) និង នាំជនសង្ស័យមកអង្គភាព ធ្វើការស្តាប់ចម្លើយ ម.៩១, ម.៩២, ម.៩៣។
- មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឃាត់ខ្លួនជនសង្ស័យ (អនុវត្តតាមនីតិវិធីឃាត់ខ្លួន) តាម ម.៩៦។

២. <u>បទឧក្រិដ្ឋ ឬ មជ្ឈិមមិនជាក់ស្តែង(ការស៊ើបអង្កេតបឋម):</u> ម.១១១-ម.១១

- មន្ត្រីនគរបាលយុត្តិធម៌ ធ្វើដោយឯកឯង ឬ តាមការប្តឹងសុំរបស់ព្រះរាជអាជ្ញា ម.១១១
- មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរ តាមនីតិវិធីស៊ើបអង្កេតបឋម ម.១១៣
- មន្ត្រីនគរបាលយុត្តិធម៌ អាចកោះហៅជនសង្ស័យឱ្យចូលខ្លួន ឬ សុំព្រះរាជអាជ្ញាចេញបញ្ជាឱ្យចូលខ្លួន ករណីរឹងទទឹង ម.១១៤
- ធ្វើការស្តាប់ចម្លើយបុគ្គលពាក់ព័ន្ធ និង ធ្វើកំណត់ហេតុ ម.១១៥
- អាចធ្វើការឃាត់ខ្លួន ម.១១៦ និង ម.៩៦ ។

៣. <u>ការប្រគល់វត្ថុដែលចាប់បានអោយម្ចាស់ដើមវិញ:</u> ម.១១៩-ម.១២០

- ព្រះរាជអាជ្ញាមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុដែលចាប់បាន នៅពេលស៊ើបអង្កេតអោយម្ចាស់ដើមវិញ (បង្គាប់ទៅមន្ត្រីនគរបាលយុត្តិធម៌ ឬ ប្រគល់ដោយខ្លួនឯង) លើកលែងវត្ថុគ្រោះថ្នាក់ ឬ ខុសច្បាប់ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោល ម១១៩ ។
- ក្នុងករណីចេញសាលក្រម បើតុលាការមិនបានសម្រេចអំពីការប្រគល់វត្ថុដែលចាប់បានទេ ព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា អាចសម្រេចដោយឯកឯង លើពាក្យសុំប្រគល់វត្ថុដែលចាប់បានអោយម្ចាស់ដើមវិញ លើកលែងវត្ថុគ្រោះថ្នាក់ ឬ ខុសច្បាប់ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោល ម១២០។

៤. <u>នីតិវិធីឆែកឆេរ:</u>

ក. បទល្មើសជាក់ស្តែង: ម.៩១

- អនុវត្តដោយមន្ត្រីនគរបាលយុត្តិធម៌
- ត្រូវមានការអនុញ្ញាតជាបឋមដោយព្រះរាជអាជ្ញា ទោះជាដោយផ្ទាល់មាត់ក៏ដោយ
- ឆែកឆេរចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ ចំពោះមុខសាក្សីពីរនាក់ ដែលមិនចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ និង មិនមែនជាមន្ត្រីនគរបាលយុត្តិធម៌ ដែលចូលរួមឆែកឆេរ។
- ម៉ោងឆែកឆេរ:

ចាប់ពីម៉ោង ៦ព្រឹក ដល់ ៦ ល្ងាច ។ ប៉ុន្តែអាចឆែកឆេរបានគ្រប់ពេលក្នុងករណី៥ចំនុចដូចខាងក្រោម:

១. តាមមាត្រា ៨៦ ករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង

២. តាមមាត្រា ៨៨ ករណីចាត់ទុកថាជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង

៣. មានសំរែកឱ្យជួយពីក្នុងទីកន្លែង

៤. ម៉ោងបើចំហសំរាប់សាធារណៈជន

៥. កន្លែងផលិត រក្សាទុក ដួញដូរ ចែកចាយ ប្រើប្រាស់ គ្រឿងញៀន

- ការឆែកឆេរនៅការិយាល័យមេធាវី:

ធ្វើដោយព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរ ប៉ុណ្ណោះ។ មន្ត្រីនគរបាលយុត្តិធម៌ ពុំមានសិទ្ធិឆែកឆេរទេ។

ការឆែកឆេរត្រូវធ្វើចំពោះមុខប្រធានគណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវី ឬ ចំពោះមុខមេធាវីសាមី។

- ការឆែកឆេរនៅក្នុងអគារសារព័ត៌មាន:

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរ តែធ្វើចំពោះមុខព្រះរាជអាជ្ញ ឬ ចៅក្រមស៊ើបសួរ ដែលធានាការឆែកឆេរ កុំឱ្យមានការប៉ះពាល់ដល់មុខរបរសេរីរបស់អ្នកសារព័ត៌មាន និង យឺតយ៉ាវដល់ការផ្សាយព័ត៌មានដោយមិនត្រឹមត្រូវ។

- កំណត់ហេតុស្តីពីការឆែកឆេរ និងការបិទស្លាកលើវត្ថុតាង: ម.៩២

១.មានចុះអំពីការអនុញ្ញាតឱ្យឆែកឆេររបស់ព្រះរាជអាជ្ញា ដោយប្រាប់ពីថ្ងៃ និង ម៉ោង នៃការអនុញ្ញាតនេះ។

២.អត្តសញ្ញាណអ្នកកាន់កាប់ទីកន្លែង ឬ សាក្សីនីមួយៗ។

៣.មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់យកវត្ថុតាង និង បិទស្លាកបោះត្រាលើវត្ថុតាងនោះ។

៤.ក្រោយពីបង្ហាញវត្ថុចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬ សាក្សីពីរនាក់មើលរួចហើយ មន្ត្រីនគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុស្តីពីការចាប់យក រួមទាំងបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក។

៤.កំណត់ហេតុស្តីពីការចាប់យក ត្រូវចុះហត្ថលេខា ឬ ផ្តិតស្រាមមេដៃដោយអ្នកកាន់កាប់ទីកន្លែង ឬ ដោយសាក្សីពីរនាក់។

ខ. ការស៊ើបអង្កេតបឋម (មិនជាក់ស្តែង): ម១១៣

- មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរ និង ចាប់យកវត្ថុតាង។

- ត្រូវមានការយល់ព្រមច្បាស់លាស់ជាលាយលក្ខណ៍អក្សរពីអ្នកកាន់កាប់ទីកន្លែង បើអ្នកកាន់កាប់នោះមិនចេះអក្សរ ត្រូវសរសេរក្នុងកំណត់ហេតុឱ្យបានច្បាស់ថា អ្នកកាន់កាប់យល់ព្រមឱ្យធ្វើការឆែកឆេរ។

- បើអវត្តមានអ្នកកាន់កាប់ ឬ អ្នកកាន់កាប់ទីកន្លែងបដិសេធការឆែកឆេរ ប្រធានសាលាដំបូងនៃទីកន្លែងនោះអាចចេញដីកាអនុញ្ញាតឱ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា។ ករណីនេះ ព្រះរាជអាជ្ញាត្រូវដឹកនាំដោយផ្ទាល់នៃការឆែកឆេរនេះ ហើយការឆែកឆេរត្រូវធ្វើចំពោះមុខសាក្សីពីរនាក់ ដែលចាត់តាំងដោយព្រះរាជអាជ្ញា ក្រៅពីកម្លាំងមន្ត្រីនគរបាលយុត្តិធម៌ ដែលចូលរួមប្រតិបត្តិការ។

- ម៉ោងឆែកឆេរពីម៉ោង ៦ ព្រឹក ដល់ ម៉ោង ៦ ល្ងាច (អត់មានករណីពិសេសមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ៦ ល្ងាច ដូចករណីជាក់ស្តែងក្នុង ម.៩១ ឡើយ)។

- វត្ថុតាងដែលចាប់យកដោយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានបិទស្លាកបោះត្រា និង ត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យក រួមជាមួយបញ្ជីសារពើភ័ណ្ឌវត្ថុដែលចាប់បាន បន្ទាប់ពីបង្ហាញឱ្យឃើញដល់អ្នកកាន់កាប់ទីកន្លែង ឬ សាក្សីពីរនាក់។

- កំណត់ហេតុស្តីពីការចាប់យក ត្រូវចុះហត្ថលេខា ឬផ្តិតស្រាមដៃពីអ្នកកាន់កាប់ទីកន្លែង ឬ សាក្សីពីរនាក់។

៥. <u>នីតិវិធីឃាត់ខ្លួន និងការបញ្ជូនខ្លួន:</u>

- ឃាត់ខ្លួនដោយមន្ត្រីនគរបាលយុត្តិធម៌ ម.៩៦។
- អ្នកដែលត្រូវឃាត់ខ្លួន: បុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស
  បុគ្គលដែលដឹងពីរឿងហេតុបទល្មើស តែបដិសេធមិនផ្តល់ព័ត៌មាន
  មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួន ដោយព្រះរាជអាជ្ញា។
- រាយការណ៍ជូនព្រះរាជអាជ្ញា និង បញ្ជូនភស្តុតាងដែលតម្រូវឱ្យមានការឃាត់ខ្លួន។
- រយៈពេលឃាត់ខ្លួននីតិជន:

៤៨ ម៉ោង គិតពីពេលមកដល់អង្គភាពមន្ត្រីនគរបាលយុត្តិធម៌ ឬករណីខ្លះគិតពីពេលដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការសួរចម្លើយចប់។

ពន្យារពេល ២៤ ម៉ោង ចំពោះបទឧក្រិដ្ឋ តែត្រូវមានការអនុញ្ញាតលាយលក្ខណ៍អក្សរ ពីព្រះរាជអាជ្ញាដែលមានសំអាងហេតុ និង ត្រូវដាក់ចូលក្នុងសំណុំរឿងផងដែរ។

ការពន្យារពេលជាវិធានការពិសេសប៉ុណ្ណោះ ហើយការពន្យារពេលនេះ មិនគិតរយៈពេលដឹកជញ្ជូនទេ។

ការពន្យារពេលមិនអាចអនុញ្ញាតទេចំពោះជនសង្ស័យជាអនីតិជន។

- រយៈពេលឃាត់ខ្លួនអនីតិជនៈ

<u>ចំពោះបទឧក្រិដ្ឋ</u>:

អនីតិជនអាយុ ពី ១៤ឆ្នាំ ដល់ ក្រោម ១៦ឆ្នាំ មិនអាចឃាត់ខ្លួនលើសពី ៣៦ម៉ោង

អនីតិជនអាយុ ពី ១៦ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ មិនអាចឃាត់ខ្លួនលើសពី ៤៨ម៉ោង។

<u>ចំពោះបទមជ្ឈិម</u>:

អនីតិជនអាយុ ពី ១៤ឆ្នាំ ដល់ ក្រោម ១៦ឆ្នាំ មិនអាចឃាត់ខ្លួនលើសពី ២៤ម៉ោង

អនីតិជនអាយុ ពី ១៦ឆ្នាំ ដល់ ក្រោម ១៨ឆ្នាំ មិនអាចឃាត់ខ្លួនលើសពី ៣៦ម៉ោង។

អនីតិជនអាយុក្រោម ១៤ ឆ្នាំ មិនអាចធ្វើការឃាត់ខ្លួនទេ។

- កំណត់ហេតុស្តីពីការឃាត់ខ្លួនៈ ម.៩៧

ពេលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រាប់ជនដែលត្រូវឃាត់ ពីសេចក្តីសម្រេចឃាត់ខ្លួន

ប្រាប់មូលហេតុពីការឃាត់ខ្លួន

ប្រាប់សិទ្ធិរកមេធាវី

រកអ្នកបកប្រែ បើចាំបាច់

ធ្វើកំណត់ហេតុដែលចុះនិទ្ទេសដូចខាងក្រោមៈ

ឈ្មោះ ឋានៈ មន្ត្រីនគរបាលយុត្តិធម៌ ដែលបង្គាប់ឱ្យធ្វើការឃាត់ខ្លួន

អត្តសញ្ញាណបុគ្គលដែលត្រូវឃាត់ខ្លួន

មូលហេតុដែលឃាត់ខ្លួន

ថ្ងៃ ខែ ឆ្នាំ ម៉ោងឃាត់ខ្លួន

ការឱ្យដំណឹងពីសិទ្ធិរកមេធាវី

ជាយថាហេតុ ឈ្មោះអ្នកបកប្រែ

- ជំនួយមេធាវីនៅក្នុងពេលឃាត់ខ្លួនៈ ម.៩៨

ផុតរយៈពេល ២៤ ម៉ោង បន្ទាប់ពីពេលចាប់ផ្ដើមឃាត់ខ្លួន បុគ្គលឃាត់ខ្លួនអាចសុំជួបសន្ទនាជាមួយមេធាវី ឬ ជនដែលខ្លួនបានជ្រើសរើសក្រៅពីអ្នកពាក់ព័ន្ធក្នុងរឿងនេះរយៈពេល ៣០ នាទី ដោយសម្ងាត់ ហើយជនដែលបានជួបសន្ទនានេះ អាចធ្វើការកត់សម្គាល់ជាលាយលក្ខណ៍អក្សរ ដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។

- ជំនួយគ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួនៈ ម.៩៩

នាពេលឃាត់ខ្លួន ព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌ អាចសុំឱ្យគ្រូពេទ្យមកពិនិត្យ ជនដែលត្រូវឃាត់ខ្លួន។

បើសុខភាពជនត្រូវឃាត់ខ្លួនមិនសមស្របនឹងការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍បន្ទាន់ទៅព្រះរាជអាជ្ញា។

គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពជនត្រូវឃាត់ខ្លួន ដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។

មន្ត្រីនគរបាលយុត្តិធម៌ចុះនិទ្ទេសការពិនិត្យសុខភាព ធ្វើដោយគ្រូពេទ្យក្នុងកំណត់ហេតុ ជាមួយឈ្មោះគ្រូពេទ្យ និង ថ្ងៃ ខែ ឆ្នាំ ម៉ោង ពិនិត្យសុខភាព។

ព្រះរាជអាជ្ញា ចុះដល់កន្លែង ដើម្បីពិនិត្យលក្ខខណ្ឌនៃការឃាត់ខ្លួន។

- ការជូនដំណឹងពេលឃាត់ខ្លួនអនីតិជនៈ ម.១០០

បើជនត្រូវឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ឪពុក ម្ដាយ អ្នកតំណាងស្របច្បាប់ ឬ អ្នកទទួលភារកិច្ចលើអនីតិជននេះ។

- បញ្ជីឃាត់ខ្លួនៈ ម.១០១

អង្គភាពមន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានបញ្ជីឃាត់ខ្លួនជាប្រចាំ ដើម្បីផ្ដល់តាមតម្រូវការរបស់អាជ្ញាធរតុលាការ។ បញ្ជីឃាត់ខ្លួន ត្រូវមានចុះនិទ្ទេសដូចខាងក្រោមៈ

ឈ្មោះ ឋានៈ មន្ត្រីនគរបាលយុត្តិធម៌ ដែលបង្គាប់ឱ្យធ្វើការឃាត់ខ្លួន

អត្តសញ្ញាណបុគ្គលដែលត្រូវឃាត់ខ្លួន

ថ្ងៃ ខែ ឆ្នាំ ម៉ោងដែលចាប់ផ្ដើមឃាត់ខ្លួន និង បញ្ចប់ការឃាត់ខ្លួន

ឈ្មោះ និង ឋានៈ ចៅក្រមដែលអនុញ្ញាតឱ្យបន្តការឃាត់ខ្លួនជាយថាហេតុ

ឈ្មោះគ្រូពេទ្យ ដែលបានពិនិត្យបុគ្គលឃាត់ខ្លួន ជាយថាហេតុ

ប្រភេទសេចក្ដីសម្រេចរបស់អាជ្ញាធរតុលាការ នៅពេលផុតកំណត់ការឃាត់ខ្លួន

- កំណត់ហេតុសរុបនៃការឃាត់ខ្លួនៈ ម.១០២

គ្រប់ការឃាត់ខ្លួន ត្រូវតែមានកំណត់ហេតុសរុបនៃការឃាត់ខ្លួន ដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។

កំណត់ហេតុសរុបនៃការឃាត់ខ្លួន ត្រូវមានចុះនិទ្ទេសដូចខាងក្រោម:

ឈ្មោះ ឋានៈ មន្ត្រីនគរបាលយុត្តិធម៌ ដែលបង្គាប់ឱ្យធ្វើការឃាត់ខ្លួន

អត្តសញ្ញាណបុគ្គលដែលត្រូវឃាត់ខ្លួន

មូលហេតុនៃការឃាត់ខ្លួន

ថ្ងៃ ខែ ឆ្នាំ ម៉ោងដែលចាប់ផ្តើមឃាត់ខ្លួន

បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា

បែបបទនៃការជូនដំណឹង ចំពោះជនត្រូវឃាត់ខ្លួន ជាអនីតិជន

ឈ្មោះគ្រូពេទ្យ ដែលបានពិនិត្យបុគ្គលឃាត់ខ្លួន

អត្តសញ្ញាណជនដែលបានសន្ទនាជាមួយបុគ្គលឃាត់ខ្លួន

ឈ្មោះ និង ឋានៈ ចៅក្រមដែលអនុញ្ញាតឱ្យបន្តការឃាត់ខ្លួនជាយថាហេតុ

ចិរវេលានៃការស្តាប់ចម្លើយនីមួយៗ និង ចិរវេលានៃការសម្រាកដែលនៅចន្លោះការស្តាប់ ចម្លើយនីមួយៗ

ថ្ងៃ ខែ ឆ្នាំ និង ម៉ោងនៃការឃាត់ខ្លួន

ប្រភេទសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការ នៅពេលបញ្ចប់ការឃាត់ខ្លួន

លក្ខខណ្ឌនៃការប្រព្រឹត្តទៅនៃការឃាត់ខ្លួន ព្រមទាំងឧប្បត្តិហេតុជាយថាហេតុ។

- ការបញ្ជូនខ្លួន: ម.១០៣

ផុតរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវឃាត់ត្រូវ:

បញ្ជូនទៅព្រះរាជអាជ្ញា ឬ

ដោះលែងឱ្យមានសេរីភាពវិញ

- រយៈពេលបញ្ជូនខ្លួន: ម.១០៤

បើបុគ្គលឃាត់ខ្លួនត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ជននោះត្រូវបញ្ជូនទៅភ្លាម

បើមិនអាចបញ្ជូនដោយមូលហេតុលំបាកក្នុងការដឹកជញ្ជូន ព្រះរាជអាជ្ញាអាចផ្តល់រយៈពេលបន្ថែម

ការបង្ហាញខ្លួនបុគ្គលឃាត់ខ្លួន ត្រូវធ្វើក្នុងរយៈពេលឆាប់បំផុតដែលអាចធ្វើបាន

កំណត់ហេតុអំពីការឃុំឃាំង ត្រូវប្រគល់ជូនព្រះរាជអាជ្ញា ដោយមន្ត្រីនគរបាលយុត្តិធម៌។

# ផ្នែកទី២: អយ្យការ

## ១. តួនាទីរបស់អយ្យការ ម២៧

- តំណាងឱ្យនីតិបុគ្គលសាធារណ:
- តំណាងអង្គការនីតិប្រតិបត្តិនៅអមសាលាជំរះក្តី ដើម្បីឃ្លាំមើលការអនុវត្តច្បាប់ និង សុំឱ្យអនុវត្តច្បាប់ក្នុងគោលដៅការពារប្រយោជន៍សង្គម
- ជំរុញបណ្តឹងអាជ្ញា ធានារ៉ាប់រងនូវការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ និងការផ្សព្វផ្សាយដីកាបង្គាប់អោយចាប់ខ្លួន។

## ២. ឋានានុក្រមអង្គការអយ្យការ ម២៩

- រដ្ឋមន្រ្តីក្រសួងយុត្តិធម៍ (អធិបញ្ញាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឱ្យចោទប្រកាន់)
- អគ្គព្រះរាជអាជ្ញា (អំណាចឋានានុក្រម)
- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង

## ៣. កិច្ចនីតិវិធីរបស់ព្រះរាជអាជ្ញា

ជម្រើសនៃការចោទប្រកាន់ ម.៤០

១. តម្កល់រឿងទុកឥតចាត់ការ ម.៤១

២. ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ម.៤៤

៣. បញ្ជូនទៅជំនុំជម្រះផ្ទាល់ ម.៤៦និង ម.៤៩

៤. នីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម ម.៤៧-ម.៤៨

១. <u>ការតម្កល់រឿងទុកឥតចាត់ការ</u>: ម.៤១

- មិនមែនជាបទល្មើសព្រហ្មទណ្ឌ
- មរណភាពជនល្មើស
- អវត្តមានបទល្មើស
- បទល្មើសតូចតាច (ជម្រើសនៃការចោទប្រកាន់)
- ការសម្រុះសម្រួលរវាងដើមបណ្តឹង និង ភាគីជនល្មើសក្នុងបទមជ្ឈិម

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវធ្វើក្នុងរយៈពេល ២ខែ គិតពីថ្ងៃចុះបញ្ជីបណ្តឹង ដោយដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ហើយគ្មានអាជ្ញាអស់ជំនុំ និងអាចធ្វើការតវ៉ាបានទៅអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ក្នុង ២ខែ បន្ទាប់ពីទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់ ។

២. ការចោទប្រកាន់ (បើកការស៊ើបសួរ)៖ ម.៤០ និង ម.៤៤

- បទឧក្រិដ្ឋត្រូវតែបើកការស៊ើបសួរ
- វត្តមានបទល្មើស
- ការស៊ើបសួរតែលើអង្គហេតុ

ការបើកការស៊ើបសួរ ធ្វើតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ ។ ករណីលេចចេញអង្គហេតុថ្មី ត្រូវមានដីកាសន្និដ្ឋានឱ្យស៊ើបសួរបន្ថែម លើកលែងអង្គហេតុនោះជាស្ថានទម្ងន់ទោស ទៅលើអង្គហេតុចាស់ ។ ចៅក្រមស៊ើបសួរ ស៊ើបសួរលើអង្គហេតុ ដែលបង្ហាញក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរប៉ុណ្ណោះ ។

៣. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់៖ ម.៤៦ និង ម.៤៩

ច្បាប់ពុំមានចែងពីលក្ខខណ្ឌនោះទេ តែអាចសន្និដ្ឋានថាអនុវត្តក្នុងរឿងបទមជ្ឈិមមិនជាក់ស្តែង ដែលផ្តន្ទាទោសតិចជាង ១ឆ្នាំ ម.៤៦ និងក្នុងបទលហុ ម.៤៩ ។

នីតិវិធី៖

- ដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់ (អត្តសញ្ញាណជនជាប់ចោទ សង្ខេបអង្គហេតុ ឈ្មោះបទល្មើស អត្ថបទច្បាប់ សិទ្ធិពឹងមេធាវី ទីកន្លែង និង កាលបរិច្ឆេទ ម៉ោង សវនាការ)
- រយៈពេលត្រូវគោរពរវាងការប្រគល់ដីកា និង ការបង្ហាញខ្លួន (ម.៤៥៧)

៤. នីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម៖ ម.៤៧-ម.៤៨ និង ម.៣០៤

មាន៤ លក្ខខណ្ឌ៖

- បទមជ្ឈិម ឬ ចាត់ទុកជាបទមជ្ឈិមជាក់ស្តែង
- ទោសត្រូវផ្តន្ទា យ៉ាងតិច ១ឆ្នាំ យ៉ាងច្រើន ៥ ឆ្នាំ
- ជនជាប់ចោទជានីតិជន

- រឿងក្ដីមានលក្ខណៈគ្រប់គ្រាន់ អាចជម្រះបាន

<u>នីតិវិធី:</u>

- ពិនិត្យអត្តសញ្ញាណ ឱ្យដំណឹងពីការចោទប្រកាន់ ឈ្មោះបទល្មើស និង សិទ្ធិពឹងពាក់មេធាវី។
- ទទួលចំលើយបុគ្គលនោះ (បើចង់និយាយ)។
- កំណត់ហេតុស្ដីពីការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម។
- ការបង្ខាំងទុកដោយកំលាំងការពារ រហូតដល់ពេលជំនុំជម្រះ។
- សវនាការត្រូវបើកនាថ្ងៃនោះតែម្ដង។
- តុលាការអាចពន្យារពេលសវនាការ តាមការសុំរបស់ជនជាប់ចោទ ឬ គំនិតខ្លួនឯង ករណីនេះតុលាការត្រូវឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន តាមសាលក្រមមុនអង្គសេចក្ដី ដោយមានសំអាងហេតុ ។
- សាលក្រមអង្គសេចក្ដី ត្រូវប្រកាសមិនលើសពី ២ សប្ដាហ៍ គិតពីថ្ងៃចូលបង្ហាញខ្លួននៅតុលាការ ។ ផុតរយៈពេលនេះ ការឃុំខ្លួនបណ្ដោះអាសន្នត្រូវបញ្ឈប់ដោយពេញច្បាប់ ។
- តុលាការក៏អាចបញ្ជូនរឿងឱ្យព្រះរាជអាជ្ញាបើកការស៊ើបសួរផងដែរ ករណីរឿងស្មុគស្មាញ ត្រូវការស្រាវជ្រាវបន្ថែម។ ករណីនេះជនជាប់ចោទត្រូវនាំទៅបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរ នៅថ្ងៃនោះតែម្ដង បើមិនដូច្នេះទេ ជនជាប់ចោទត្រូវដោះលែងឱ្យមានសេរីភាពដោយឯកឯង ។

## ផ្នែកទី៣: ចៅក្រមស៊ើបសួរ

### ១. សមត្ថកិច្ចដែនដី: ម.១២៣

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬ ទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- វិវាទសមត្ថកិច្ចចៅក្រមស៊ើបសួរសាលាដំបូងខុសគ្នា ត្រូវសម្រេចដោយប្រធានសភាស៊ើបសួរ
- វិវាទសមត្ថកិច្ចសភាស៊ើបសួរ ត្រូវសម្រេចដោយប្រធានតុលាការកំពូល
- ការសេម្រេចបិទផ្លូវតវ៉ា។

## ២. នីតិវិធីបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី: ម.១៣៨-ម.១៤១

១. <u>ការដាក់ពាក្យបណ្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី</u>: ម.១៣៨

- បណ្តឹងដាក់ទៅចៅក្រមស៊ើបសួរ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីដោយមេធាវី
- ចៅក្រមស៊ើបសួរកត់សម្គាល់បណ្តឹងតាមដីកា និង បញ្ជូនទៅព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរតាម ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (អាចប្រឆាំងអញ្ញាតជន ទោះបណ្តឹងចោទប្រកាន់បុគ្គលម្នាក់ក៏ដោយ)
- ព្រះរាជអាជ្ញាអាចសុំចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរក្នុង ២ ករណី: ម.១៣៩
  - ក. បណ្តឹងអាជ្ញា ត្រូវបានផុតរលត់
  - ខ. អំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌជាដើម
- ករណីចៅក្រម សម្រេចមិនស៊ើបសួរ ត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយជូនដំណឹងបន្ទាន់ទៅដើមបណ្តឹងរដ្ឋប្បវេណី (អាចប្តឹងឧទ្ធរណ៍)
- ករណីចៅក្រម សម្រេចស៊ើបសួរ ត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយជូនដំណឹងបន្ទាន់ទៅព្រះរាជអាជ្ញា (អាចប្តឹងឧទ្ធរណ៍)។

២. <u>ការបង់ប្រាក់តម្កល់</u>: ម.១៤០

- ការសម្រេចឱ្យបង់ប្រាក់តាមដីកាសម្រេច (កំណត់ចំនួនទឹកប្រាក់ និង រយៈពេលត្រូវបង់)
- ឬ លើកលែងប្រាក់តម្កល់ តាមដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ (ជូនដំណឹងទៅដើមបណ្តឹងរដ្ឋ/ណី)
- បង្កាន់ដៃបង់ប្រាក់មានចុះហត្ថលេខាដោយប្រធាន ព្រះរាជអាជ្ញា និង ក្រឡាបញ្ជី
- ប្រាក់តម្កល់ទុកនៅក្នុងគណនីពិសេស នៅធនាគារ ឬ កន្លែងមានការធានាសន្តិសុខរឹងមាំ តាមការព្រមព្រៀងរបស់ប្រធានតុលាការ និង ព្រះរាជអាជ្ញា

៣. <u>ការបង់ប្រាក់ពិន័យចំពោះបណ្តឹងបំពាន</u>: ម.១៤១

- ករណីមានដីកាសម្រេចលើកលែងចោទប្រកាន់
- ចៅក្រមអាចសម្រេចតាមដីកាសម្រេចឱ្យបង់ប្រាក់ពិន័យ មិនលើសពីចំនួនទឹកប្រាក់តម្កល់ (ជូនដំណឹងដល់ដើមបណ្តឹងរដ្ឋ/ណី)

- បុគ្គលដែលមានឈ្មោះក្នុងពាក្យប្តឹង អាចប្តឹងសុំការជួសជុលសំណង ពេលដីកាលើកលែងចោទប្រកាន់ស្ថាពរ។

៣. វិធានការណ៍ស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ:

- ការជូនដំណឹងពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ ម.១៤៣: (កំណត់ហេតុស្តីពីការបង្ហាញខ្លួនដំបូង)
- ការសួរចម្លើយជនត្រូវចោទ ម.១៤៥
- ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ម.១៥០
- ការស្តាប់ចម្លើយសាក្សី ម.១៥៣
- ការឆែកឆេរ និង ចាប់យកវត្ថុតាង ម.១៥៩-ម.១៦០
- ការប្រគល់វត្ថុដែលចាប់យកអោយម្ចាស់ដើមវិញ ម.១៦១
- កោសលវិច័យ ម.១៦២
- ការស្តាប់ទូរស័ព្ទ ម.១៧២
- ដីកាចាត់ឱ្យស៊ើបសួរជំនួស ម.១៣១, ម.១៧៣-ម.១៧៤

៤. វិធានការណ៍និវន្តរាយ:

- ដីកាបង្គាប់ឱ្យចូលខ្លួន ម.១៨៦
- ដីកាបង្គាប់ឱ្យនាំខ្លួន ម.១៨៩: បើត្រូវបានឃុំតាមដីកានេះ ត្រូវរាប់បញ្ចូលក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ម.១៨៤។
- ដីកាបង្គាប់ឱ្យចាប់ខ្លួន ម.១៨៩៦: ដីកាបង្គាប់ឱ្យចាប់ខ្លួន: ការចាប់ និង នាំទៅពន្ធនាគារតែម្តង។ លក្ខខណ្ឌដីកាចាប់:

១. បទឧក្រិដ្ឋ ឬ មជ្ឈិម ដែលផ្តន្ទាទោសដាក់ពន្ធនាគារ

២. មានការគេចខ្លួន ឬ មិនដឹងស្ថិតនៅកន្លែងណា ឬ ស្ថិតនៅក្រៅដែនដី

៣. ជូនដំណឹងទៅព្រះរាជអាជ្ញា និង ទទួលយោបល់ព្រះរាជអាជ្ញា មុនចេញដីកាចាប់ខ្លួន

៤. ព្រះរាជអាជ្ញា ធានារ៉ាប់រងផ្សព្វផ្សាយដីកាចាប់ខ្លួន។

បើត្រូវបានឃុំតាមដីកានេះ ត្រូវរាប់បញ្ចូលក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ម.២០២។

## ៥. នីតិវិធីឃុំខ្លួនបណ្តោះអាសន្ន: ម២០៦

១. កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង: (ម.១៤៣)

- ការពិនិត្យអត្តសញ្ញាណជនត្រូវចោទ
- ប្រាប់រឿងរ៉ាវចោទប្រកាន់ និង ឈ្មោះបទល្មើស
- ការប្រាប់សិទ្ធិឆ្លើយ ឬ មិនឆ្លើយដោយសេរី
- ប្រាប់សិទ្ធិជ្រើសរើសមេធាវី ឬ សុំឱ្យចាត់តាំងមេធាវី

២. កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ: (ម.២០៦)

- ការជូនដំណឹងជនត្រូវចោទ ពីការសម្រេចឃុំខ្លួនបណ្តោះអាសន្ន
- ការទទួលការកត់សំគាល់របស់ជនត្រូវចោទ
- ការបង្ហាញមធ្យោបាយការពារខ្លួនរបស់មេធាវីជនត្រូវចោទ (បើមាន)
- វត្តមានព្រះរាជអាជ្ញា ឬ ការផ្តល់ដីកាសន្និដ្ឋានស្នើសុំឱ្យឃុំខ្លួនបណ្តោះអាសន្ន
- ដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន (ជូនដំណឹងដល់ព្រះរាជអាជ្ញា និង ជនត្រូវចោទ)
- ដីកាបង្គាប់ឱ្យឃុំខ្លួនទៅប្រធានពន្ធនាគារ។

## ៦. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះ នីតិជន

<u>បទឧក្រិដ្ឋ</u>: ម.២០៨ (៦+៦+៦ ខែ)

- មិនអាចលើសពី ៦ ខែ អាចពន្យារពេលបាន ២ ដង តាមដីកាមានសំអាងហេតុ (ការពន្យារពេល ត្រូវធ្វើនីតិវិធីដេញដោលចំពោះមុខ ដូចនីតិវិធីឃុំបណ្តោះអាសន្នដែរ)។

<u>បទមជ្ឈិម</u> ម.២០៩ (៤+២ ខែ)

- មិនអាចលើសពី ៤ ខែ អាចពន្យារពេលបានម្តងគត់ មិនលើសពី ២ ខែ (ការពន្យារពេលធ្វើនីតិវិធីដូចក្នុងបទឧក្រិដ្ឋដែរ)
- ថិរវេលាឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈិមខាងលើ មិនអាចលើសពីពាក់កណ្តាលអប្បបរមានៃទោសដែលច្បាប់កំណត់ឡើយ (យកអប្បបរមានៃទោស ចែកនឹង២)។

## ៧. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះ អនីតិជន:

<u>បទឧក្រិដ្ឋ</u> ម.២១៣

- អាយុ ១៤ ដល់ ក្រោម ១៦ ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្ន មិនលើសពី ៤ ខែ
- អាយុ ១៦ ដល់ ក្រោម ១៨ ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្ន មិនលើសពី ៦ ខែ

<u>បទមជ្ឈិម</u> ម.២១៤

- អាយុ ១៤ ដល់ ក្រោម ១៦ ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្ន មិនលើសពី ២ ខែ
- អាយុ ១៦ ដល់ ក្រោម ១៨ ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្ន មិនលើសពី ៤ ខែ
- ក្នុងបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្ន មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់កំណត់សម្រាប់អនីតិជនឡើយ (យកអប្បបរមានៃទោស ចែកនឹង២ រួចចែកនឹង២ម្ដងទៀត)។

<u>កត់សំគាល់:</u>

- អនីតិជន អាយុក្រោម ១៤ ឆ្នាំ មិនអាចឃុំខ្លួនបណ្ដោះអាសន្នឡើយ
- ការពន្យារពេលឃុំខ្លួនបណ្ដោះអាសន្ន សម្រាប់អនីតិជន ពុំមានឡើយ
- ការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងបទល្មើសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ការឃុំខ្លួនបណ្ដោះអាសន្ន គឺ ១ឆ្នាំ ពន្យារពេលបាន ២ ដង: (១+១+១) ឆ្នាំ ។

## ៨. នីតិវិធីបិទការស៊ើបសួរ (ម.២៤៦)

១. <u>ការជូនដំណឹង និងការស្នើសុំឱ្យបំពេញកិច្ច:</u>

- កាលណាចៅក្រមស៊ើបសួរ មានបំណងបិទការស៊ើបសួរ ត្រូវជូនដំណឹងដល់ភាគីទាំងអស់ (ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី)។
- ក្នុងដំណាក់កាលនេះ ជនត្រូវចោទ (ម.១៣៣) ដើមបណ្ដឹងរដ្ឋប្បវេណី (ម.១៣៤) និងមេធាវី អាចស្នើសុំដល់ចៅក្រមស៊ើបសួរ ឱ្យបំពេញកិច្ចបន្ថែមលើចំនុចណាដែលខ្លួនយល់ថាមានប្រយោជន៍ ។

២. <u>ការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា និងការស្នើសុំឱ្យបំពេញកិច្ច:</u>

- រយៈពេល ២ថ្ងៃ ក្រោយពីការជូនដំណឹងទៅភាគី អំពីគោលបំណងបិទការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ (ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ)។
- ប្រសិនបើយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មី ព្រះរាជអាជ្ញាធ្វើការស្នើសុំទៅចៅក្រមស៊ើបសួរឱ្យធ្វើការបំពេញកិច្ចបន្ថែម (ម.១៣២)។
- ប្រសិនបើព្រះរាជអាជ្ញា យល់ឃើញដូចចៅក្រមស៊ើបសួរ ថាការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និង មានសំអាងហេតុ ប្តឹងសុំទៅចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងចោទប្រកាន់។
- ការបង្វិលសំណុំរឿងពីព្រះរាជអាជ្ញា ដោយមានភ្ជាប់ជាមួយដីកាសន្និដ្ឋានស្ថាពរ:

  ១៥ ថ្ងៃ បើជនត្រូវចោទនៅក្នុងឃុំ

  ១ ខែ បើជនត្រូវចោទនៅក្រៅឃុំ

  រយៈពេលខាងលើគិតពីថ្ងៃព្រះរាជអាជ្ញា បានទទួលសំណុំរឿង។

## ៩. ដីកាដំណោះស្រាយ (ម.២៤៧)

១. <u>ដីកាបញ្ជូនទៅជំនុំជម្រះ</u>:

ប្រសិនបើយល់ឃើញថា អំពើនោះជា បទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ចៅក្រមស៊ើបសួរ សម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ដីកានេះត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើស តាមច្បាប់។

ដីកាបញ្ជូនទៅជំនុំជម្រះ សរសេរនូវសេចក្តីសម្រេចដោយឡែកពីការរក្សាជនត្រូវចោទក្នុងឃុំរយៈពេល ៤ខែ រហូតដល់បង្ហាញមុខចំពោះតុលាការជំនុំជម្រះ ម.២៤៩។

២. <u>ដីកាលើកលែងចោទប្រកាន់</u>:

- អំពើប្រព្រឹត្ត មិនមែនជាបទល្មើស
- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ

ចៅក្រមស៊ើបសួរ មិនត្រូវជាប់កាតព្វកិច្ច គោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។

ចៅក្រមស៊ើបសួរ មិនត្រូវជាប់កាតព្វកិច្ច គោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។

ដីកាដំណោះស្រាយត្រូវជូនដំណឹងដល់ ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវី ក្នុងរយៈពេលខ្លីបំផុត។

នៅក្នុងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរសម្រេចអំពីការប្រគល់សងទៅអោយម្ចាស់ដើមវិញ នូវវត្ថុដែលចាប់យក ម.២៤៨។

## ផ្នែកទី៤: ចៅក្រមជំនុំជម្រះ

### ១. សមត្ថកិច្ចរបស់សាលាដំបូង: ម.២៨៩

- សាលាដំបូងជំនុំជម្រះបទ ឧក្រិដ្ឋ មជ្ឈិម និង លហុ
- សាលាដំបូងសម្រេចជាក្រុមសមូហភាពដែលមានចៅក្រម ៣រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុ ដែលជាប់ទាក់ទង
- សាលាដំបូងសម្រេចជាចៅក្រមទោល ចំពោះបទមជ្ឈិម និងបទលហុ។

### ២. វិវាទសមត្ថកិច្ចរវាងសាលាដំបូង: ម.២៩០

តុលាការដែលមានសមត្ថកិច្ចដែនដី:

- តុលាការនាទីកន្លែងបទល្មើស
- តុលាការនាទីលំនៅឋានរបស់ជនជាប់ចោទ
- តុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ

ករណីតុលាការពីរ ឬច្រើន ក្នុងមណ្ឌលនៃសាលាឧទ្ធរណ៍តែមួយ ប្រធានសាលាឧទ្ធរណ៍ជាអ្នកសម្រេច ហើយបិទផ្លូវតវ៉ា។

វិវាទសមត្ថកិច្ចដែនដីរវាងតុលាការច្រើនមានថ្នាក់ស្មើគ្នា ត្រូវសម្រេចដោយប្រធានតុលាការជាន់ខ្ពស់។ បើវិវាទនៅសាលាដំបូង គឺប្រធានសាលាឧទ្ធរណ៍ជាអ្នកសម្រេច ហើយបិទផ្លូវតវ៉ា។ បើវិវាទនៅសាលាឧទ្ធរណ៍ គឺប្រធានតុលាការកំពូលជាអ្នកសម្រេច ហើយបិទផ្លូវតវ៉ា។

- ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់ដោយព្រះរាជអាជ្ញា (CD)
- កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមធ្វើដោយព្រះរាជអាជ្ញា (CI)

បុគ្គលដែលបញ្ជូនតាមដីកាខាងលើមានឈ្មោះថា ជនជាប់ចោទ។ ជនរងគ្រោះនៃបទល្មើស អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាននៅចំពោះមុខតុលាការ ប្រសិនបើខ្លួនមិនទាន់បានតាំងខ្លួននៅឡើយនៅចំពោះមុខចៅក្រមស៊ើបសួរ ។

## ៤. ដែនកំណត់នៃការប្តឹងទៅតុលាការ (ម៣៤៨-៣៤៩)

១- <u>ដែនកំណត់ចំពោះអង្គហេតុ</u>: ម.៣៤៨

- តុលាការអាចសម្រេចសេចក្តីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា។
- ក្នុងករណីសម្រេចជាក្រុម បើយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះ បង្កើតជាបទមជ្ឈិម ឬលហុ តុលាការនោះនៅតែមានសមត្ថកិច្ចដើម្បីជម្រះសេចក្តីដដែល។
- ក្នុងករណីសម្រេចជាចៅក្រមទោល បើយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះ បង្កើតជាបទឧក្រិដ្ឋ តុលាការនោះបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ។

២- <u>ដែនកំណត់ចំពោះបុគ្គល</u>: ម.៣៤៩

- តុលាការអាចជំនុំជម្រះបុគ្គលដែលបញ្ជូនទៅចំពោះមុខខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ។
- បើបុគ្គលដែលកោះហៅជាសាក្សី ត្រូវបានចោទប្រកាន់ក្នុងឋានៈជា ជនដៃដល់ ឬអ្នកសមគំនិត បុគ្គលនោះនឹងអាចត្រូវជំនុំជម្រះបាន ក្រោយពីត្រូវបានចោទប្រកាន់ តាម ម.៤៣។

# ផ្នែកទី៥: នីតិវិធីសម្រាប់បណ្តឹងឧទ្ធរណ៍

**- សាលក្រម**

ហាលាដំបូងអាចចេញសាលក្រមក្នុងរឿងព្រហ្មទណ្ឌ តាមពីររបៀបដូចខាងក្រោម:

១- សាលក្រមចំពោះមុខជនជាប់ចោទ:

ក្នុងករណីដែលជនជាប់ចោទមានវត្តមានក្នុងពេលសវនាការ នោះសាលក្រមដែលត្រូវចេញដោយតុលាការ ហៅថា សាលក្រមចំពោះមុខជនជាប់ចោទ។

សាលក្រម នៅតែជាសាលក្រមចំពោះមុខដដែល ក្នុងករណីដែលជនជាប់ចោទចាកចេញពីបន្ទប់សវនាការ និងក្នុងករណីដែលជនជាប់ចោទពុំអាចបង្ហាញខ្លួនក្នុងពេលសវនាការ ដោយសារមូលហេតុស្ថានភាព ឬ មូលហេតុធ្ងន់ធ្ងរណាមួយ ហើយត្រូវបានសួរចម្លើយតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះសាលក្រមចំពោះមុខជនជាប់ចោទ គឺ មិនត្រូវបានជូនដំណឹងជនជាប់ចោទទេ ហើយក៏មិនផ្តល់សិទ្ធិឱ្យប្តឹងទាស់ដែរ ប៉ុន្តែអាចប្តឹងឧទ្ធរណ៍បាន (មាត្រា ៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ក្រៅពីលក្ខខណ្ឌខាងលើ សាលក្រមត្រូវបានចាត់ទុកជាចំពោះមុខផងដែរក្នុងករណីដូចខាងក្រោម:

- ប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលសវនាការ ប៉ុន្តែ សាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬដឹងពីការកោះហៅ នោះសាលក្រម ត្រូវចាត់ទុកជាសាលក្រមចំពោះមុខជនជាប់ចោទ។ ចំពោះសាលក្រមដែលត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខនេះ ត្រូវជូនដំណឹងដល់ជនជាប់ចោទ និងបើកផ្លូវប្តឹងឧទ្ធរណ៍ តែពុំអនុញ្ញាតឱ្យប្តឹងទាស់ទេ (មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

២- សាលក្រមកំបាំងមុខជនជាប់ចោទ:

ក្នុងករណីដែលជនជាប់ចោទអវត្តមានក្នុងពេលសវនាការ ហើយពុំមានភស្តុតាងណាបញ្ជាក់ថា ជនជាប់ចោទបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬការកោះហៅទៅជំនុំជម្រះ នោះសាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវជូនដំណឹងដល់ជនជាប់ចោទ ហើយអនុញ្ញាតឱ្យជនជាប់ចោទ ប្តឹង

ទាស់បាន (មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ អ្នកប្តឹងទាស់អាចមានលទ្ធភាពប្តឹងឧទ្ធរណ៍បន្ថែមទៀត ចំពោះសាលក្រមសម្រេចលើបណ្តឹងទាស់ផងដែរ (មាត្រា៣៧១ និង ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

## II- បណ្តឹងទាស់

ពិរុទ្ធជន អាចធ្វើបណ្តឹងទាស់នឹងសាលក្រម ដែលប្រកាសដោយកំបាំងមុខខ្លួនបាន (មាត្រា ៣៦៥)។

### ១- រយៈពេលប្តឹងទាស់:

បណ្តឹងទាស់ត្រូវធ្វើឡើងក្នុងរយៈពេល១៥ថ្ងៃ ផ្តើមគិត:

- ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃ។ ឬ
- ពីថ្ងៃដែលពិរុទ្ធជនបានដឹងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនោះ មិនបានប្រគល់ឲ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃ (មាត្រា ៣៦៨)។

### ២- ទម្រង់ និងភាពអាចទទួលយកបាននៃបណ្តឹងទាស់:

បណ្តឹងទាស់ត្រូវធ្វើពាក្យប្តឹងជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ឬនៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ឬ នៅចំពោះមុខប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។ ពិរុទ្ធជនត្រូវតំណាងដោយមេធាវី ហើយមេធាវីត្រូវតែមានលិខិត អនុញ្ញាតឲ្យធ្វើបណ្តឹងទាស់ (លិខិតប្រគល់សិទ្ធិ)។ ប៉ុន្តែក្នុងករណីដែលពិរុទ្ធជនជាអនីតិជន គឺពិរុទ្ធជនរូបនោះ អាចត្រូវតំណាងដោយឪពុក ម្តាយ ឬ អាណាព្យាបាល ហើយក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។

ព្រះរាជអាជ្ញា អង្គភាពនគរបាល កងរាជអាវុធហត្ថ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន កាលណាទទួលបានពាក្យប្តឹងទាស់ ត្រូវបញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ អ្នកប្តឹងទាស់ត្រូវចុះហត្ថលេខា ឬ ផ្តិតម្រាមដៃលើពាក្យប្តឹងទាស់ (មាត្រា ៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៣- អានុភាពនៃបណ្តឹងទាស់:

កាលណាបណ្តឹងទាស់ធ្វើឡើងប្រឆាំងនឹងសាលក្រមទាំងមូល នោះសាលក្រមនេះត្រូវចាត់ទុកជាអសារបង់ ហើយការអនុវត្តសាលក្រមត្រូវព្យួរ ដើម្បីរងចាំសេចក្តីសម្រេចលើបណ្តឹងទាស់នោះសិន ប៉ុន្តែ ដីកាបង្គាប់ឱ្យចាប់ខ្លួន នៅតែមានអានុភាព ហើយតុលាការនៅតែមានសមត្ថកិច្ចដើម្បីសម្រេចអំពីការដោះលែងជនជាប់ចោទ ឱ្យមានសេរីភាពឡើងវិញ។

កាលណាបណ្តឹងទាស់ធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី គឺមានតែសេចក្តីសម្រេចផ្នែកនេះប៉ុណ្ណោះទេដែលត្រូវទុកជាអសារបង់ ហើយការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីត្រូវព្យួរ (មាត្រា ៣៧០)។

៤- សាលក្រមសម្រេចលើបណ្តឹងទាស់:

ក្នុងករណីដែលមានបណ្តឹងទាស់ គឺសំណុំរឿងត្រូវបានលើកយកមកជំនុំជម្រះនៅចំពោះមុខតុលាការដដែល ហើយភាគីទាំងអស់ត្រូវបានកោះហៅតាមគំនិតផ្តើមរបស់ព្រះរាជអាជ្ញា។ ក្រោយពីបានពិនិត្យលើភាពអាចទទួលបាននៃបណ្តឹងទាស់ តុលាការត្រូវសម្រេចលើអង្គសេចក្តីជាថ្មីម្តងទៀត។ ប្រសិនបើអ្នកប្តឹងទាស់ដែល បានកោះហៅត្រឹមត្រូវ ហើយមិនចូលបង្ហាញខ្លួននាពេលសវនាការទេ តុលាការត្រូវប្រកាសថាបណ្តឹងទាស់ទុកជាឯកសារឥតបានការ។ ក្នុងករណីនេះ សាលក្រមដែលត្រូវប្តឹងទាស់មិនអាចកែប្រែបានទេ ហើយសាលក្រមនេះ នឹងមានអានុភាពទាំងស្រុងចំពោះភាគីទាំងអស់ផងដែរ (មាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

## III- បណ្តឹងឧទ្ធរណ៍

III-១) បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

១- បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេច:

បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (ទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍) ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរនៅសាលាដំបូង ដើម្បីទាមទារឱ្យវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ ភាពមិនត្រឹមត្រូវនៃដីកាសម្រេចនោះ។

បុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរបានរួមមាន:

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និង ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង: អាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរទាំងអស់ រួមទាំងដីកាដំណោះស្រាយផងដែរ (មាត្រា ២៦៦)។

- ជនត្រូវចោទ: អាចប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដូចមានចែងក្នុង (មាត្រា ២៦៧)។

- ដើមបណ្តឹងរដ្ឋប្បវេណី: អាចប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដូចមានចែងក្នុង (មាត្រា ២៦៨)។

- គ្រប់បុគ្គលនៅក្រៅនីតិវិធីស៊ើបសួរអនុលោមតាមមាត្រា ១៦១ (ការប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ ដោយចៅក្រមស៊ើបសួរ) ដែលមានចែងក្នុងមាត្រា ២៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍:

បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវធ្វើក្នុងរយៈពេល១ (មួយ) ខែ យ៉ាងយូរគិតពីពេលប្រកាសដីកា។

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវធ្វើក្នុងរយៈពេល៥ (ប្រាំ) ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីដីកានេះ។

បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងរបស់បុគ្គលដែលមានចែងក្នុងមាត្រា ២៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវធ្វើក្នុងរយៈពេល៥ (ប្រាំ) ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីដីកានេះ។

ប្រសិនបើការជូនដំណឹងធ្វើឡើងដោយការប្រគល់សេចក្តីចម្លងនៃដីកាដោយមានចំណារទទួល នោះរយៈពេលបណ្តឹងឧទ្ធរណ៍ ផ្តើមគិតចាប់ពីកាលបរិច្ឆេទនៃចំណារទទួលនោះ (មាត្រា ២៧០ ក្រមនីតិវិធីព្រហ្មទណ្ឌ)។

៣- ទម្រង់នៃបណ្តឹងឧទ្ធរណ៍ ទីកន្លែងដាក់ពាក្យបណ្តឹង និងការបញ្ជូនសំណុំរឿង:

បណ្តឹងឧទ្ធរណ៍ត្រូវធ្វើតាមការប្រកាសប្តឹងនៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង ហើយបណ្តឹងឧទ្ធរណ៍ត្រូវចុះក្នុងបញ្ជីនៃបណ្តឹងឧទ្ធរណ៍របស់តុលាការជាន់ដំបូងនោះ។

ប្រសិនបើការជូនដំណឹងធ្វើឡើងដោយការប្រគល់សេចក្តីចម្លងនៃដីកាដោយមានចំណារទទួល នោះរយៈពេលបណ្តឹងឧទ្ធរណ៍ ផ្តើមគិតចាប់ពីកាលបរិច្ឆេទនៃចំណារទទួលនោះ (មាត្រា ២៧០ ក្រមនីតិវិធីព្រហ្មទណ្ឌ)។

៣- ទម្រង់នៃបណ្តឹងឧទ្ធរណ៍ ទីកន្លែងដាក់ពាក្យបណ្តឹង និងការបញ្ជូនសំណុំរឿង:

បណ្តឹងឧទ្ធរណ៍ត្រូវធ្វើតាមការប្រកាសប្តឹងនៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង ហើយបណ្តឹងឧទ្ធរណ៍ត្រូវចុះក្នុងបញ្ជីនៃបណ្តឹងឧទ្ធរណ៍របស់តុលាការជាន់ដំបូងនោះ។

បណ្តឹងឧទ្ធរណ៍អាចត្រូវធ្វើដោយមេធាវីរបស់ជនត្រូវចោទ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬ របស់បុគ្គលដែលមានចែងក្នុងមាត្រា២៦៩ (បណ្តឹងឧទ្ធរណ៍ចំពោះដីកាបដិសេធមិនប្រគល់វត្ថុដែលរឹបអូសទៅម្ចាស់ដើមវិញ) នៃក្រមនេះ។

បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទដែលត្រូវបានឃុំខ្លួន ត្រូវធ្វើតាមការប្រកាសប្តឹងនៅមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវប្រគល់ភ្លាមនូវលិខិតប្តឹងឧទ្ធរណ៍មួយច្បាប់ជូនទៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង ហើយលិខិតនេះត្រូវបញ្ចូលទៅក្នុងបញ្ជីនៃបណ្តឹងឧទ្ធរណ៍ (មាត្រា ២៧២)។

កាលណាបានទទួលបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៅតុលាការជាន់ដំបូង ត្រូវជូនដំណឹងភ្លាមដល់ចៅក្រមស៊ើបសួរ។ ក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរ ត្រូវរៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរ ដោយមានសេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍ភ្ជាប់ជាមួយផង។ សេចក្តីចម្លងនេះ ត្រូវធ្វើដោយក្រឡាបញ្ជីនៃតុលាការជាន់ដំបូង ក្រោយពីបានឃើញនិទ្ទេសដែលចុះក្នុងបញ្ជីបណ្តឹងឧទ្ធរណ៍។ សំណុំរឿងនេះត្រូវបញ្ជូនទៅការិយាល័យ ក្រឡាបញ្ជីនៃសភាស៊ើបសួរ នៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈដែលមិនអាចជំនះបាន (មាត្រា ២៧៣)។

III-២) បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម

១- បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម:

២- រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍:

- រយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា:

ការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវតែធ្វើក្នុងរយៈពេល ១ (មួយ) ខែ ។

ការប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាត្រូវតែធ្វើក្នុងរយៈពេល ៣ (បី) ខែ។

រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលប្រកាសសាលក្រម (មាត្រា៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

- រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី:

ការប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវតែធ្វើក្នុងរយៈពេល ១ (មួយ) ខែ ។ កាលណាសាលក្រមនោះ ជាសាលក្រមចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលប្រកាសសាលក្រម ហើយបើសាលក្រមនោះ ជាសាលក្រមចាត់ទុកជាចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឲ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ (មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

- រយៈពេលបន្ថែមសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍: បណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុ:

ក្នុងករណីដែលភាគីណាមួយបានប្តឹងឧទ្ធរណ៍នៅក្នុងរយៈពេលខាងលើនេះ ភាគីដទៃទៀតមានរយៈពេលបន្ថែម ៧ (ប្រាំពីរ) ថ្ងៃ ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុ ហើយរយៈពេលបន្ថែមនេះ ផ្តើមគិតពីការផុតរយៈពេលធម្មតា (មាត្រា ៣៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

- រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងពិរុទ្ធជន ក្នុងករណីមានការឃុំខ្លួន:

ក្នុងរឿងឃុំខ្លួន ការប្តឹងឧទ្ធរណ៍ត្រូវតែធ្វើដោយព្រះរាជអាជ្ញានៅក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង និងដោយពិរុទ្ធជន ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ផ្តើមគិតពីថ្ងៃដែលតុលាការសម្រេចពីការឃុំខ្លួន (មាត្រា ៣៨៤)។

- បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមចាត់របៀប:

កាលណាតុលាការចេញសាលក្រមចាត់របៀប បណ្តឹងឧទ្ធរណ៍អាចត្រូវទទួលបានភ្លាម ប្រសិនបើសាលក្រមនេះបញ្ចប់នីតិវិធី។ ក្នុងករណីផ្ទុយពីនេះ សាលក្រមចាត់របៀបនឹងអាចត្រូវដាក់ជូនសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែធ្វើព្រមគ្នាជាមួយសាលក្រមលើអង្គសេចក្តី (មាត្រា ៣៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៣- ទម្រង់នៃបណ្តឹងឧទ្ធរណ៍ ទីកន្លែងដាក់ពាក្យបណ្តឹង និងការបញ្ជូនសំណុំរឿង:

ការប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើតាមការពាក្យប្តឹងនៅក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ហើយលិខិតប្តឹងឧទ្ធរណ៍នោះ ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអគ្គព្រះរាជអាជ្ញា (មាត្រា ៣៧៨)។

ចំពោះបណ្តឹងឧទ្ធរណ៍របស់ ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម (មាត្រា ៣៧៦)។

ចំពោះពិរុទ្ធជនដែលជាប់ឃុំ អាចសំដែងឆន្ទៈរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍នៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ពិរុទ្ធជន ត្រូវបំពេញពាក្យប្តឹងឧទ្ធរណ៍ដែលត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ហើយពាក្យប្តឹងឧទ្ធរណ៍នេះត្រូវចុះបញ្ជីដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួននៅលើបញ្ជីពិសេស និង ពិរុទ្ធជនត្រូវចុះហត្ថលេខានៅលើរឹមនៃបញ្ជីនេះផងដែរ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍នៅក្នុង រយៈពេលដ៏ខ្លីបំផុត ទៅក្រឡាបញ្ជីនៃតុលាការដែលត្រូវចុះនិទ្ទេសអំពីពាក្យប្តឹងឧទ្ធរណ៍នេះ នៅលើបញ្ជីបណ្តឹងឧទ្ធរណ៍នៃតុលាការ (មាត្រា ៣៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី ហើយមេធាវីរូបនោះត្រូវតែមានលិខិតប្រគល់សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍។ ចំពោះពិរុទ្ធជនជាអនីតិជន អាចតំណាងដោយឪពុក ម្តាយ ឬ អ្នកអាណាព្យាបាល ដោយមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។

ចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់ ហើយអ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍ផងដែរ។ លិខិតប្តឹងឧទ្ធរណ៍ត្រូវតែចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹងឧទ្ធរណ៍ ឬ អ្នកតំណាង។ លិខិតប្រគល់សិទ្ធិត្រូវភ្ជាប់ជាមួយនឹងលិខិត

ប្តឹងឧទ្ធរណ៍ (មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ កាលណាអ្នកប្តឹងឧទ្ធរណ៍មិនចេះចុះហត្ថលេខា អ្នកប្តឹងឧទ្ធរណ៍ត្រូវផ្តិតម្រាមដៃ (មាត្រា ៣៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ក្រោយពេលមានបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ក្នុងរយៈពេលដ៏ខ្លីបំផុតជូនទៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍នូវ៖

- សំណុំរឿងនៃនីតិវិធី
- សេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍នីមួយៗដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម
- សេចក្តីចម្លងនៃសាលក្រមដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។

ក្នុងករណីបណ្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការស្តីពីការឃុំខ្លួនជនជាប់ចោទ សំណុំរឿងត្រូវបញ្ជូនក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរ គិតពីថ្ងៃប្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជំនះបាន ដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន (មាត្រា ៣៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

នៅពេលសំណុំរឿងបញ្ជូនទៅដល់សាលាឧទ្ធរណ៍ ប្រធានសភាព្រហ្មទណ្ឌត្រូវពិនិត្យផ្ទៀងផ្ទាត់មើលថា តើទម្រង់បែបបទនៃបណ្តឹងឧទ្ធរណ៍បានត្រឹមត្រូវឬទេ និងកំណត់កាលបរិច្ឆេទនៃសវនាការ។ ក្នុងករណីបណ្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការជាន់ដំបូងស្តីពីការឃុំខ្លួនជនជាប់ចោទ សាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងរយៈពេលដ៏ខ្លីបំផុត និងយ៉ាងយូរបំផុតក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលសំណុំរឿង (មាត្រា ៣៨៧)។

៤- អានុភាពនៃបណ្តឹងឧទ្ធរណ៍៖

នៅក្នុងរយៈពេលប្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រមត្រូវបង្អង់សិន។ ប៉ុន្តែជនជាប់ចោទដែលជាប់ឃុំដែលបានចូលបង្ហាញខ្លួននៅមុខតុលាការដំបូង ត្រូវនៅក្នុងពន្ធនាគារនៅក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងនៅក្នុងករណីមានបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងព្រហ្មទណ្ឌ នោះជនជាប់ចោទត្រូវនៅក្នុងពន្ធនាគាររហូតដល់សាលាឧទ្ធរណ៍សម្រេច (មាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៥- ប្រភេទនៃសាលដីកា៖

សាលដីកាដែលប្រកាសដោយសាលាឧទ្ធរណ៍អាចជា សាលដីកាចំពោះមុខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខ ឬជាសាលដីកាកំបាំងមុខ តាមការវែកញែកដែលអនុវត្តចំពោះសាលក្រមដែលប្រកាសដោយ តុលាការជាន់ដំបូង (មាត្រា ៤០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៦- បណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ:

នីតិវិធីនៃបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ អនុវត្តដូចគ្នាទៅនឹងសាលក្រមកំបាំងមុខដែរ សូមមើលចាប់ពីមាត្រា ៤០៩ ដល់ ៤១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

## IV- បណ្តឹងសាទុក្ខ

១- បណ្តឹងសាទុក្ខចំពោះសាលដីការបស់សភាស៊ើបសួរ និងសាលដីការបស់សភាព្រហ្មទណ្ឌ:

បណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (ទៅសភាព្រហ្មទណ្ឌនៃតុលាការកំពូល) ចំពោះសាលដីកានៃសភាស៊ើបសួរ ដោយគិតរួមបញ្ចូលទាំងរឿងបត្យាប័ន ព្រមទាំងសាលដីកាដែលសម្រេចជាសមត្ថកិច្ចចុងក្រោយដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។ ប៉ុន្តែ នីតិវិធីតវ៉ានេះមិនអាចធ្វើបានទេ ចំពោះសាលដីកានៃសភាស៊ើបសួរ ដែលបង្គាប់ឱ្យបញ្ជូនជនជាប់ចោទទៅតុលាការជំនុំជម្រះ មានន័យថាចំពោះសាលដីការបស់សភាស៊ើបសួរដែលបង្គាប់ឱ្យបញ្ជូនជនជាប់ចោទទៅតុលាការជំនុំជម្រះ គឺបិទផ្លូវតវ៉ា (មាត្រា ៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

បុគ្គលដែលអាចធ្វើបណ្តឹងសាទុក្ខបានរួមមាន:

- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ជនជាប់ចោទ ឬ ពិរុទ្ធជន
- បុគ្គលដែលត្រូវគេទាមទារ ក្នុងករណីនៃនីតិវិធីបត្យាប័ន
- ដើមបណ្តឹងរដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

បណ្តឹងសាទុក្ខ ត្រូវពិនិត្យដោយសភាព្រហ្មទណ្ឌនៃតុលាការកំពូល (មាត្រា ៤១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

២- រយៈពេលធ្វើបណ្តឹងសាទុក្ខៈ បណ្តឹងសាទុក្ខត្រូវធ្វើឡើងក្នុងរយៈពេលៈ

- ១ (មួយ) ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍

- ១៥ (ដប់ប្រាំ) ថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍

- ៥ (ប្រាំ) ថ្ងៃ ចំពោះមតិរបស់សភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន

កាលណាសាលដីកាដែលប្តឹងសាទុក្ខនេះ ជាសាលដីកាចំពោះមុខ រយៈពេលត្រូវផ្តើមគិតពីការប្រកាសសាលដីកា។

កាលណាសាលដីកាដែលប្តឹងសាទុក្ខ ជាសាលដីកាចាត់ទុកថាចំពោះមុខ រយៈពេលត្រូវផ្តើមគិតពីការឱ្យដំណឹង។

កាលណាសាលដីកាសម្រេចដោយកំបាំងមុខ រយៈពេលត្រូវផ្តើមគិតពីការផុតរយៈពេលប្តឹងទាស់ (មាត្រា ៤២០)។

- បណ្តឹងសាទុក្ខចំពោះសាលដីកាចាត់របៀបៈ

កាលណាសាលាឧទ្ធរណ៍ចេញសាលដីកាចាត់របៀប បណ្តឹងសាទុក្ខត្រូវទទួលបានភ្លាម ប្រសិនបើសាលដីកានេះបញ្ចប់នីតិវិធី។ ក្នុងករណីផ្ទុយពីនេះ សាលដីកាចាត់របៀបអាចដាក់ជូនតុលាការកំពូលពិនិត្យជាមួយគ្នានឹងសាលដីកាលើអង្គសេចក្តីតែប៉ុណ្ណោះ (មាត្រា ៤២១ ក្រមនីតិវិធីព្រហ្មទណ្ឌ)។

៣- ទម្រង់នៃបណ្តឹងសាទុក្ខ ទីកន្លែងដាក់ពាក្យបណ្តឹង និងការបញ្ជូនសំណុំរឿងៈ

បណ្តឹងសាទុក្ខត្រូវធ្វើតាមពាក្យបណ្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលបានចេញសេចក្តីសម្រេច។ ពាក្យប្តឹងនេះត្រូវចុះក្នុងបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនេះ។

ជនជាប់ចោទ ពិរុទ្ធជន និងបុគ្គលដែលត្រូវគេទាមទារក្នុងក្របខណ្ឌនីតិវិធីបត្យាប័ន អាចតំណាងដោយ មេធាវី ហើយមេធាវីត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យប្តឹងសាទុក្ខ។ ប៉ុន្តែជនជាប់ចោទ ឬ ពិរុទ្ធជន ជាអនីតិជន អាចត្រូវតំណាងដោយឪពុក ម្តាយ ឬ អ្នកអាណាព្យាបាល ហើយមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។

ចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចតំណាងដោយមេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់ ហើយអ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងសាទុក្ខផងដែរ (មាត្រា ៤២២)។

បណ្ដឹងសាទុក្ខ ត្រូវតែចុះហត្ថលេខាដោយក្រឡាបញ្ជី និង អ្នកប្ដឹង ឬ អ្នកតំណាង។ កាលណាអ្នកប្ដឹងមិនចេះចុះហត្ថលេខាទេ សាមីខ្លួន ឬអ្នកតំណាងត្រូវផ្ដិតម្រាមដៃ។ លិខិតប្រគល់សិទ្ធិ ត្រូវភ្ជាប់ជាមួយនឹងពាក្យសុំប្ដឹងសាទុក្ខ។ ប្រសិនបើខ្វះហត្ថលេខារបស់ក្រឡាបញ្ជី ឬខ្វះកាលបរិច្ឆេទ ពាក្យប្ដឹងសាទុក្ខអាចទទួលបាន ប្រសិនបើគ្មានឃើញការបន្ថែមអ្វីទេ តែក្រឡាបញ្ជីត្រូវរងទោសពិន័យ ៥,០០០ (ប្រាំពាន់) រៀល ហើយប្រាក់ពិន័យនេះ ត្រូវប្រកាសដោយតុលាការកំពូលនៅក្នុងសាលដីការបស់ខ្លួន (មាត្រា ៤២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ក្រោយពេលទទួលបណ្ដឹងសាទុក្ខ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅក្រឡាបញ្ជីនៃតុលាការកំពូល (មាត្រា ៤២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៤- អានុភាពនៃបណ្ដឹងសាទុក្ខៈ

នៅក្នុងរយៈពេលសម្រាប់ធ្វើបណ្ដឹងសាទុក្ខ ការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ត្រូវបង្អង់សិន រងចាំតុលាការកំពូលធ្វើសេចក្ដីសម្រេច។ ប៉ុន្តែការអនុវត្តដាក់ពន្ធនាគារមិនត្រូវបង្អង់ទេ នៅក្នុងករណីដែលជនជាប់ចោទបានបង្ហាញខ្លួននៅមុខសាលាឧទ្ធរណ៍ក្នុងឋានៈជាជនជាប់ឃុំនោះ។ ក្នុងករណីនេះគឺៈ

- ដីកាបង្គាប់ឲ្យចាប់ខ្លួននៅតែមានអានុភាព
- ការឃុំខ្លួនបណ្ដោះអាសន្ននៅតែបន្តអនុវត្ត
- បុគ្គលជាប់ឃុំនៅក្នុងក្របខ័ណ្ឌនីតិវិធីបត្យាប័ន នៅតែជាប់ឃុំដដែល
- ក្នុងករណីមានការសម្រេចឲ្យរួចខ្លួន ជនជាប់ចោទត្រូវបានដោះលែងឲ្យមានសេរីភាព (មាត្រា ៤៣៥)។

៥- សាលដីកាចំពោះបណ្ដឹងសាទុក្ខៈ

តុលាការកំពូលធ្វើការពិចារណាលើបណ្ដឹងសាទុក្ខ ដោយពិនិត្យលើបញ្ហាច្បាប់ដែលមានរៀបរាប់ក្នុង សារណា មាត្រា ៤៣៦)។ កាលណាការចោទប្រកាន់មិនមែនជាបទល្មើស តុលាការកំពូលត្រូវប្រកាសបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ដោយគ្មានបង្វិលសំណុំរឿងទៅវិញឡើយ (មាត្រា ៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

កាលណាតុលាការកំពូលយល់ឃើញថា អំពើដែលចោទប្រកាន់នោះ ជាបទល្មើសផ្សេងអំពីបទល្មើសនៅក្នុងសេចក្តីសម្រេចដែលគេតវ៉ា ប៉ុន្តែ បទល្មើសនេះត្រូវបានផ្តន្ទាទោសដូចគ្នា នោះតុលាការកំពូលមិនចាំបាច់ប្រកាសបដិសេធ គឺអាចកែប្រែប្រភេទគតិយុត្តនៃអង្គហេតុថ្មី ដោយរក្សាទោសដែលបានប្រកាសហើយ និងសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៅដដែល។

កាលណាតុលាការកំពូលយល់ឃើញថា អំពើដែលចោទប្រកាន់នោះ ជាបទល្មើសផ្សេងអំពីបទល្មើសនៅក្នុងសេចក្តីសម្រេចដែលគេតវ៉ា ប៉ុន្តែ បទល្មើសនេះត្រូវបានផ្តន្ទាទោសផ្សេង នោះតុលាការកំពូលត្រូវបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងបង្គាប់ឲ្យបញ្ជូនរឿងទៅសាលាជម្រះក្តីមានសមត្ថកិច្ចដើម្បីជំនុំជម្រះ (មាត្រា ៤៤១)។

ប្រសិនបើតុលាការទទួលសំណុំរឿងបង្វិល មិនអនុលោមតាមសាលដីកាទី១របស់តុលាការកំពូលទេ ហើយប្រសិនបើមធ្យោបាយដែលត្រូវបានលើកឡើងមកធ្វើជាសម្អាងសម្រាប់បណ្តឹងសាទុក្ខលើកទី២ នោះតុលាការកំពូលដែលជំនុំជម្រះសភាពេញអង្គ (ចៅក្រម ៩រូប) ត្រូវសម្រេចលើអង្គហេតុ និងអង្គច្បាប់ ដោយចេញសាលដីកាស្ថាពរមួយ (មាត្រា ៤៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

## V- បណ្តឹងសើរើ

១-និយមន័យ:

បណ្តឹងសើរើ គឺជាផ្លូវតវ៉ាមួយប្រឆាំងនឹងសាលក្រម និងសាលដីកាដែលស្ថាពរ ហើយដែលមានអាជ្ញាអស់ជំនុំ។ សភាពេញអង្គនៃតុលាការកំពូលជាអ្នកមានសមត្ថកិច្ចលើបណ្តឹងសើរើនេះ (មាត្រា ៤៤៣)។

បណ្តឹងសើរើ អាចត្រូវធ្វើបាននៅក្នុងរឿងព្រហ្មទណ្ឌ ទោះបីតុលាការដែលបានសម្រេចនោះជាតុលាការណាក៏ដោយ និងទោះបីទោសដែលបានប្រកាសនោះជាទោសអ្វីក៏ដោយ (មាត្រា ៤៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

២-លក្ខខណ្ឌ និងបុគ្គលដែលអាចប្តឹងសើរើ:

បណ្តឹងសើរើរឿងក្តី អាចធ្វើបានតែក្នុងករណីដូចខាងក្រោម:

- កាលណាក្រោយពីការផ្តន្ទាទោសពីបទមនុស្សឃាត ស្រាប់តែមានលេចតម្រុយយ៉ាងគ្រប់គ្រាន់ ដែលអនុញ្ញាតឲ្យគិតថាជនរងគ្រោះនោះនៅរស់រានមានជីវិតនៅឡើយ

- កាលណាជនជាប់ចោទពីរនាក់ត្រូវផ្តន្ទាទោស ចំពោះបទល្មើសដដែលនេះ ដោយការផ្តន្ទាទោសទាំងពីរនេះមិនចុះសម្រុងគ្នាទេ

- កាលណាសាក្សីណាមួយត្រូវបានផ្តន្ទាទោស ពីបទល្មើសធ្វើជាសាក្សីដោយក្លែងប្រឆាំងនឹងជនជាប់ចោទ

- កាលណាមានអង្គហេតុថ្មី ឬលិខិត ឬភស្តុតាងថ្មី ដែលនាំឲ្យគេសង្ស័យលើពិរុទ្ធភាពនៃទណ្ឌិត (មាត្រា ៤៤៥)។

បុគ្គលដែលអាចប្តឹងសើរើរឿងក្តីបានរួមមាន:

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- ទណ្ឌិត ឬ អ្នកតំណាងស្របច្បាប់ ប្រសិនបើទណ្ឌិតនេះជាអសមត្ថជន

- សហព័ទ្ធ ឪពុក ម្តាយ កូន និងជាទូទៅ ជនណាដែលមានប្រយោជន៍ខាងសម្ភារៈ ឬ ខាងផ្លូវចិត្តក្នុងការលប់បំបាត់ទណ្ឌកម្មនេះ ក្នុងករណីដែលទណ្ឌិតបានទទួលមរណភាព ឬ បាត់ខ្លួន។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មុននឹងទៅប្តឹងតុលាការកំពូល អាចសុំដល់អគ្គព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាង ដែនដីឲ្យធ្វើការស្រាវជ្រាវបន្ថែមភស្តុតាងថ្មី ដែលនាំឲ្យគេសង្ស័យលើពិរុទ្ធភាពនៃទណ្ឌិត (មាត្រា ៤៤៦)។

៣- រយៈពេលធ្វើបណ្តឹងសើរើ:

ក្រឡាបញ្ជីត្រូវផ្តល់ដល់ដើមបណ្តឹងថា ខ្លួនមានរយៈពេល ៣០ (សាមសិប) ថ្ងៃ ដើម្បីបំពេញពាក្យប្តឹងរបស់ខ្លួន។ រយៈពេលនេះអាចពន្យារបានដោយប្រធានតុលាការកំពូល។ នៅពេលដែលផុតរយៈពេលនេះ ប្រធានតុលាការកំពូលត្រូវចាត់តាំងចៅក្រមរបាយការណ៍ម្នាក់។ កាលណារបាយការណ៍ធ្វើរួចហើយ សំណុំរឿងត្រូវបញ្ជូនទៅអគ្គព្រះរាជអាជ្ញាតុលាការកំពូល ដើម្បីធ្វើដីកាសន្និដ្ឋានជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ (មាត្រា ៤៤៨)។

## ៤- ការបញ្ជូនសំណុំរឿង និងសាលដីការបស់តុលាការកំពូលៈ

នៅពេលដែលសភាព្រហ្មទណ្ឌទទួលបណ្តឹងសើរើ សភាព្រហ្មទណ្ឌអាចសម្រេចព្យួរការអនុវត្តទោសបាន ប្រសិនបើមានមូលហេតុច្បាស់លាស់ (មាត្រា ៤៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ប្រសិនបើសភាព្រហ្មទណ្ឌសម្រេចថា បណ្តឹងសើរើអាចទទួលយកបាននោះ សភាព្រហ្មទណ្ឌត្រូវបញ្ជូនសំណុំរឿងនៃបណ្តឹងសើរើទៅតុលាការកំពូល ដើម្បីជំនុំជម្រះជាសភាពេញអង្គ និងសម្រេចលើអង្គហេតុ និង អង្គច្បាប់ ដោយសាលដីកាស្ថាពរ (មាត្រា ៤៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។